# ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

# វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

THE IMPACT OF DOLLARIZATION ON THE CAMBODIA ECONOMY

## ជំនាញ គណនេយ្យ

**រាជធានីភ្នំពេញ-ឆ្នាំ២០២៤**

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

**VANDA INSTITUTE**

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

THE IMPACT OF DOLLARIZATION ON THE CAMBODIA ECONOMY

សាស្ត្រាចារ្យណែនាំ ៖ យ៉ែម សុខហៀក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទ៖ ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

សាស្ត្រាចារ្យណែនាំ

យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ក វុទ្ធី

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

ប្រធានគណៈកម្មការវាយតម្លៃ និង
ជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

(Impression)

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំ យល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ ហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



គ្រី ណាំស្រ៊ី
ID: B21/2292



តូ ស្រីពេជ
ID: B21/2271



មឿន លី
ID: B21/3315



ព្រហ្ម ភីរ៉ា
ID: B21/3318

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រគណនេយ្យជំនាន់ទី២១ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា។

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **យ៉េម សុខហៀក** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមខ្ញុំបាទ នាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា" នេះគឺជាស្នាដៃរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ..... ...... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រោយការណែនាំ និងការលើកទឹកចិត្តពីថ្នាក់ដឹកនាំនៃវិទ្យាស្ថានវ៉ាន់ដា វិទ្យាស្ថានបានផ្តល់ឱកាសសម្រាប់ក្រុមយើងខ្ញុំក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញ គណនេយ្យ លើប្រធានបទ **ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា** អត្ថបទនេះត្រូវបានសរសេរក្នុងគោលបំណងសិក្សាស្វែងយល់ពីប្រវត្តិដុល្លារ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ ការគ្រប់គ្រងប្រាក់ដុល្លារ គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ដុល្លារមកលើសេដ្ឋកិច្ច។

នាពេលបច្ចុប្បន្ននេះពិភពលោកទាំងមូលស្ទើរតែគ្រប់ប្រទេសទាំងអស់ សុទ្ធសឹងតែអនុវត្តនូវប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ ក្នុងការអនុវត្តប្រព័ន្ធសេដ្ឋកិច្ចនេះការកំណត់នូវរូបិយវត្ថុជាកត្តាចាំបាច់សម្រាប់ធ្វើពាណិជ្ជកម្មលក្ខណៈជាតិ និងអន្តរជាតិជាមធ្យោបាយដោះដូរទៅលើថ្លៃទំនិញនិងសេវាផ្សេងៗ។ ជាក់ស្តែងក្នុងប្រទេសកម្ពុជាបានប្រើប្រាស់ប្រាក់ដុល្លារជំនួសឱ្យរូបិយវត្ថុជាតិ (**ប្រាក់រៀល**) ក្នុងការធ្វើពាណិជ្ជកម្មនានា ការដោះដូរ ការទូទាត់ទំនិញ និងសេវាកម្មនានា ការរក្សាទុកជាពិសេសក្នុងវិស័យធនាគារភាគច្រើនការដាក់ប្រាក់សន្សំ និងការផ្តល់ប្រាក់កម្ចីសុទ្ធសឹងជាប្រាក់ដុល្លារ។ ការចរាចរប្រាក់ដុល្លារនៅក្នុងសេដ្ឋកិច្ចកម្ពុជាបានធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើនទៅលើវិស័យមួយចំនួនដូចជា វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម វិស័យធនាគារ និងហិរញ្ញវត្ថុ និងកសាងហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិ។ លើសពីនេះទៅទៀតជួយសម្រួលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកស្ទួយកំណើនអ្នកវិនិយោគមកវិនិយោគក្នុងប្រទេសកម្ពុជាដើម្បីសម្រួលដល់ជីវភាពការងារប្រជាពលរដ្ឋផងដែរ។ ទន្ទឹមនិងនេះការប្រើប្រាស់ប្រាក់ដុល្លារក៏បានផ្តល់នៅគុណវិបត្តិជាច្រើនមកលើសេដ្ឋកិច្ចផងដែរដូចជា ប៉ះពាល់ដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ បាត់បង់ចំណូលពីបោះពុម្ពក្រដាសប្រាក់រៀល ហានិភ័យនៃអត្រាប្តូរប្រាក់ពេលទិញ-លក់ទំនិញ ការបាត់បងទំនុកចិត្តក្នុងការប្រើប្រាស់រៀល។

តាមរយៈអត្ថបទខាងលើក្រុមយើងយល់ឃើញថា ការប្រើប្រាស់ដុល្លារពិតជាមានភាពងាយស្រួលជាងការប្រើប្រាស់ប្រាក់រៀល ដោយសារតែប្រាក់ដុល្លារជារូបិយបណ្ណមួយប្រភេទដែលបានគ្របដណ្តប់ប្រទេសទូទាំងសកលលោក ម្យ៉ាងទៀតដុល្លាររូបនីយកម្មក៏បានចូលរួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ចកម្ពុជាគួរឱ្យកត់សម្គាល់ ហើយក៏បានផ្តល់នូវគុណវិបត្តិមួយចំនួនផងដែរ។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធ ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

## ជំពូកទី១
## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២

១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## រំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅនៃផលប៉ះពាល់ដុល្លារូបនីយកម្ម ........ ៤

២.១.១ និយមន័យ ........ ៤

២.១.២ ប្រវត្តិនៃប្រាក់ដុល្លារ ........ ៤

២.១.៣ ទ្រឹស្តីនៃដុល្លារូបនីយកម្ម ........ ៤

២.២ ផលប៉ះពាល់នៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច ........ ៥

២.២.១ និយមន័យ ........ ៥

២.២.២ ប្រវត្តិសេដ្ឋកិច្ចពិភពលោក ........ ៦

២.២.៣ ទ្រឹស្តីនៃសេដ្ឋកិច្ច ........ ៨

២.៣ គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិដើម្បីគ្រប់គ្រងដុល្លារូបនីយកម្ម ........ ៩

២.៣.១ និយមន័យ ........ ៩

២.៣.២ ប្រវត្តិ ........ ១០

២.៣.៣ ទ្រឹស្តីនៃធនាគារ ........ ១៣

## ជំពូកទី៣
## លទ្ធផលនៃការស្រាវជ្រាវ


៣.១ ស្ថានភាពទូទៅនៃដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ........ ១៣
៣.១.១ ប្រវត្តិធនាគារជាតិ នៃកម្ពុជា ........ ១៣
៣.១.២ បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា ........ ១៧
៣.១.៣ មុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ........ ១៧
៣.១.៤ រចនាសម្ព័ន្ធរបស់ធនាគារនៃកម្ពុជា ........ ១៨
៣.២ ផលប៉ះពាល់នៃដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ........ ១៩
៣.២.១ ដុល្លាររូបនីយកម្មនៅកម្ពុជា ........ ២០
៣.២.២ ប្រភេទនៃដុល្លាររូបនីយកម្ម ........ ២១
៣.២.៣ គុណសម្បត្តិ និងគុណវិបត្តិនៃដុល្លាររូបនីយកម្ម ........ ២២
៣.៣ គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិដើម្បីគ្រប់គ្រងដុល្លាររូបនីយកម្ម ........ ២៥
៣.៣.១ ប្រភេទនៃគោលនយោបាយរូបិយវត្ថុ ........ ២៦
៣.៣.២ គោលដៅនៃគោលនយោបាយរូបិយវត្ថុ ........ ២៧
៣.៣.៣ គោលនយោបាយរូបិយវត្ថុនៃធនាគារជាតិ ដើម្បីគ្រប់គ្រងដុល្លាររូបនីយកម្ម ........ ២៨


## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ........ ២៩
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៣០


## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ........ ៣១
៥.២ ការផ្តល់អនុសាសន៍ ........ ៣២
ឯកសារយោង
ឧបសម្ព័ន្ធ

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅ រូបិយវត្ថុត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមតំបន់នៃប្រទេសនីមួយៗ ក្នុងទម្រង់ជាច្រើនប្រភេទដូចជាមាស ក្រដាសប្រាក់ វត្ថុមានតម្លៃ និងការប្រើប្រាស់ជារូបិយវត្ថុអេឡិចត្រូនិចជាដើម។ ដើម្បីទ្រទ្រង់សេដ្ឋកិច្ច និងជួយសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឱ្យមានភាពងាយស្រួលប្រទេសជាតិនីមួយៗបានបង្កើតនូវរូបិយវត្ថុរបស់ខ្លួនដើម្បីជាមធ្យោបាយដោះដូរ កំណត់ឯកត្តានៃតម្លៃ និងជាមធ្យោបាយសន្សំ។ ប្រជាពលរដ្ឋបានប្រើប្រាស់រូបិយវត្ថុនៅក្នុងការប្រកបមុខរបរជាប្រចាំថ្ងៃដូចជា ការទូទាត់ទៅលើថ្លៃទំនិញ សេវាកម្ម ការសន្សំ ការផ្តល់ប្រាក់កម្ចី ឥណទាន និងការប្រើប្រាស់ផ្សេងៗទៀតទៅតាមតម្រូវការរបស់ពួកគេ។ ក្នុងការដាក់ចរាចរនូវរូបិយវត្ថុទៅក្នុងសេដ្ឋកិច្ច ដោយមានធនាគារកណ្តាលទទួលបន្ទុកជាអ្នកបោះពុម្ពផ្សាយរូបិយវត្ថុហើយរូបិយវត្ថុមិនត្រឹមតែជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋនោះទេ គឺថែមទាំងជួយសម្រួលដល់រាជរដ្ឋាភិបាលនៅក្នុងការអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ច គោលនយោបាយពន្ធដារ ការចំណាយទៅលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងដើម្បីឱ្យប្រទេសជាតិទាំងមូលឆ្ពោះទៅដល់សេដ្ឋកិច្ចមួយដែលមានវិវឌ្ឍនាការ។

តួយ៉ាងការបើកចំហសេដ្ឋកិច្ចទីផ្សារសេរី បានធ្វើឱ្យមានកំណើននៃការវិនិយោគមកពីតាមបណ្តាប្រទេសផ្សេងៗជាច្រើនទាំងក្នុងទ្វីបអាស៊ី និងអឺរ៉ុប។ ការទទួលជំនួយពីបរទេសធ្វើឱ្យមានការចរាចរនូវរូបិយបណ្ណបរទេសជាច្រើនទៅក្នុងសេដ្ឋកិច្ចដែលគួរឱ្យកត់សម្គាល់ជាពិសេសប្រទេសដែលកំពុងអភិវឌ្ឍ។ វត្តមាននៃរូបិបណ្ណទាំងនេះបានធ្វើឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់ជំនួសរូបិយវត្ថុជាតិបានដោយសារស្ថិរភាពនៃតម្លៃរូបិយបណ្ណ ទាំងនេះធៀបទៅនិងរូបិយវត្ថុជាតិ។ លើសពីនេះទៅទៀតរូបិយបណ្ណបរទេសមានសារៈសំខាន់យ៉ាងច្រើននៅក្នុងសេដ្ឋកិច្ចសម្រាប់ការធ្វើពាណិជ្ជកម្មការនាំចេញនាំចូលនូវវត្ថុធាតុដើម គ្រឿងទេស និងសម្ភារៈសម្រាប់ប្រើប្រាស់ផ្សេងៗទៀតជាដើម។ ស្ថានភាពរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចនៅក្នុងប្រទេសដែលកំពុងអភិវឌ្ឍមានរូបិយបណ្ណរបស់ប្រទេសជាច្រើនបានធ្វើការចរាចរនៅក្នុងសេដ្ឋកិច្ច ដោយប្រជាពលរដ្ឋបានយករូបិយបណ្ណទាំងនោះយកមកប្រើប្រាស់ជាពិសេសប្រាក់ដុល្លារអាមេរិក។ លើសពីនេះទៅទៀតការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅក្នុងទីផ្សារសេដ្ឋកិច្ច គឺដើរទន្ទឹមគ្នានិងការប្រើប្រាស់រូបិយវត្ថុជាតិនៅក្នុងការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ។

ស្ថានភាពសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាប្រាក់ដុល្លារអាមេរិកបានធ្វើការចរាចរនៅក្នុងទីផ្សារសេដ្ឋកិច្ចយ៉ាងច្រើនលើសលប់ផងដែរ គឺវាដើរទន្ទឹមគ្នានិងការប្រើប្រាស់រូបិយវត្ថុជាតិ " **ប្រាក់រៀល**" ។ អស់រយៈពេលជាងពីរសតវត្សមកហើយប្រជាពលរដ្ឋកម្ពុជាបានប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ក្នុងការទូទាត់សម្រាប់ប្រតិបត្តិការសេដ្ឋកិច្ចជាច្រើនទាំងនៅក្នុងទីក្រុង និងនៅតាមទីជនបទដែរបានផ្តល់ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ។ ដោយហេតុដែលបានរៀបរាប់ខាងលើនេះទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយស្តីពី"**ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**" ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្ថានភាពបច្ចុប្បន្ន ដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជាត្រូវបានគេប្រើប្រាស់ជាមធ្យោបាយសម្រាប់ដោះដូរ ទូទាត់ថ្លៃទំនិញឬសេវាកម្ម និងសម្រាប់ការសន្សំ។ តម្លៃទំនិញភាគច្រើនត្រូវគិតជាលុយដុល្លារការទិញលក់ភាគច្រើនត្រូវទូទាត់ដោយប្រើលុយដុល្លារហើយការដាក់លុយសន្សំនៅធនាគារភាគច្រើនត្រូវដាក់ជាដុល្លារ។ ការអនុញ្ញាតឱ្យប្រើប្រាស់នូវប្រាក់ដុល្លារយ៉ាងទូលំទូលាយបែបនេះអាចផ្តល់នូវគុណប្រយោជន៍មួយចំនួនប៉ុន្តែ ក៏អាចបង្កនូវផលប៉ះពាល់អវិជ្ជមានច្រើនផងដែរដល់សេដ្ឋកិច្ចកម្ពុជា។

ហេតុដូច្នេះទើបក្រុមយើងខ្ញុំមានសំណួរមួយចំនួនចោទសួរដូចខាងក្រោម៖

១.តើដុល្លារូបនីយកម្មមានផលប៉ះអ្វីខ្លះមកលើសេដ្ឋកិច្ចកម្ពុជា ?

២.តើធនាគារជាតិត្រូវមានគោលនយោបាយរូបិយវត្ថុអ្វីខ្លះ ដើម្បីគ្រប់គ្រងដុល្លារូបនីយកម្មនៅកម្ពុជា ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺចង់បង្ហាញពីដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា៖

- ☞ សិក្សាពីប្រវត្តិធនាគារជាតិនៃកម្ពុជា
- ☞ សិក្សាពីស្ថានភាពដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា
- ☞ សិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចកម្ពុជា
- ☞ សិក្សាពីគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើ«**ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើកសេដ្ឋកិច្ចកម្ពុជា**»ហើយការស្រាវជ្រាវនេះសិក្សាពីម៉ាក្រូសេដ្ឋកិច្ចកម្ពុជាជាពិសេស ធនាគារជាតិនៃកម្ពុជាពីព្រោះជាធនាគារកណ្តាលដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចដែលជាអ្នកគ្រប់គ្រងដុល្លារូបនីយកម្ម ព្រមទាំងជាអ្នកទទួលបន្ទុកដោយផ្ទាល់លើបរិមាណផ្គត់ផ្គង់រូបិយវត្ថុ និងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ទីស្នាក់ការកណ្តាលរបស់ធនាគារជាតិនៃកម្ពុជាដែលមានអាសយដ្ឋាន៖ អគារលេខ២២៧៣ ផ្លូវលេខ១១០ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដំណើរការនៃការស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីឆ្លុះបញ្ចាំងពីតថភាពនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០២២-២០២៣ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឱ្យដំណើរការនៃការសរសេរសារណាទៅលើប្រធានបទស្តីពី "**ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**" ឱ្យបានជោគជ័យក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវ និងការប្រមូលទិន្នន័យតាមរយៈការស្រាវជ្រាវ៖ គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គេហទំព័រធនាគារជាតិ ស្រាវជ្រាវនៅតាមបណ្ណាល័យនានា សារណារៀមច្បង តាមរយៈប្រព័ន្ធអ៊ិនធឺណិត និងមានសាស្ត្រាចារ្យជួយណែនាំ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវ គឺជាការនាំមកនូវការអភិវឌ្ឍផ្នែកចំណេះដឹងរបស់និស្សិតបន្ថែមមួយកម្រិតទៀតដើម្បីយល់ដឹងពីសកម្មភាពនានាក្នុងការទំនាក់ទំនង និងប្រតិបត្តិការមួយចំនួននៅក្នុងសង្គមបច្ចុប្បន្ន។

សារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ គឺផ្តល់នូវចំណេះដឹងដល់ក្រុមនាងខ្ញុំដូចជា៖

- បង្កើនចំណេះដឹងបន្ថែមទៅលើការសិក្សាស្រាវជ្រាវ ក៏ដូចជាស្វ័យសិក្សា
- មានបទពិសោធន៍ក្នុងការវិភាគរកដំណោះស្រាយបញ្ហានានា
- មានទំនាក់ទំនងល្អក្នុងការសហការគ្នាធ្វើការងារជាក្រុម
- ស្គាល់ពីស្ថានភាពប្រាក់ដុល្លារូបនីយកម្មក្នុងសេដ្ឋកិច្ចកម្ពុជា
- យល់ដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើងដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់នូវចំណុចនីមួយៗ និងធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមាន សេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណង វិធីសាស្រ្ត សារៈសំខាន់នៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន ការផ្តល់អនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាស្រាវជ្រាវរួចមកក្រុមយើងខ្ញុំក៏បានបែងចែកជាប្រាំជំពូកដែលបានរៀបរាប់ដូចខាងក្រោម៖

**ជំពូកទី១៖ (សេចក្តីផ្តើម)** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណងមូលហេតុនៃការស្រាវជ្រាវ ចំណោទបញ្ហា ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖ (រំលឹកទ្រឹស្តី)** បង្ហាញពីនិយមន័យ ប្រវត្តិទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធ និងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ (លទ្ធផលនៃការស្រាវជ្រាវ)** បង្ហាញពីស្ថានភាពដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា គោលនយោបាយ និងបេសកម្មរបស់ធនាគារជាតិនៃកម្ពុជា។

**ជំពូកទី៤៖ (ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ)** វិភាគ និងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។

**ជំពូកទី៥៖ (សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍)** សេចក្តីសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច

## ២.១ លក្ខណៈទូទៅនៃផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ច

### ២.១.១ និយមន័យ

**ផលប៉ះពាល់** គឺជាឥទ្ធិពលនៃអ្វីមួយទៅលើអ្វីមួយទៀត[1]។

**ដុល្លារូបនីយកម្ម** មិនមែនសំដៅតែទៅលើការប្រើប្រាក់ដុល្លាជំនួសរូបិយវត្ថុក្នុងស្រុកប៉ុណ្ណោះនោះទេ តែជាកម្រិតនៃប្រតិបត្តិការនៅក្នុងវិស័យសេដ្ឋកិច្ចពិត និងវិស័យហិរញ្ញវត្ថុ ដែលប្រើប្រាស់នូវប្រាក់ដុល្លាអាមេរិកដោយប្រៀបធៀបជាមួយនឹងប្រតិបត្តិការ ដែលប្រើប្រាស់រូបិយបណ្ណក្នុងស្រុក[2]។

**ដុល្លារូបនីយកម្ម** គឺជាបាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយ បានជ្រើសរើសប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ឬរូបិយបណ្ណបរទេសដទៃទៀតជំនួសឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ[3]។

**ដុល្លារូបនីយកម្ម** គឺជាការចាប់យករូបិយបណ្ណរបស់បរទេសណាមួយ សម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ[4]។

**ដុល្លារូបនីយកម្ម** គឺជាការអនុម័តស្របច្បាប់នៃប្រាក់ដុល្លារអាមេរិក ឬរូបិយបណ្ណរបស់ប្រទេសមួយផ្សេងទៀតជារូបិយបណ្ណក្នុងស្រុករបស់ប្រទេសទីពីរ[5]។

### ២.១.២ ប្រវត្តិនៃប្រាក់ដុល្លារ

ប្រាក់ដុល្លារ គឺជារូបិយបណ្ណផ្លូវការរបស់សហរដ្ឋអាមេរិកចាប់តាំងពីការអនុម័តច្បាប់រូបិយបណ្ណជាតិឆ្នាំ ១៧៨៥។ មុននោះសហរដ្ឋអាមេរិកបានប្រើរូបិយបណ្ណប្រទេសផ្សេង គឺផោនអង់គ្លេស និងរូបិយបណ្ណបរទេសផ្សេងៗ។ ដំបូងឡើយប្រាក់ដុល្លារត្រូវបានគេដាក់ឈ្មោះជាកាក់តែប៉ុណ្ណោះដោយក្រដាសប្រាក់ត្រូវបានដាក់ប្រើនៅឆ្នាំ១៨៦១ ហើយតម្លៃរបស់វាត្រូវបានគេគិតភ្ជាប់ជាមួយតម្លៃមាស ប្រាក់ និងទង់ដែង។ សភាអាមេរិកបានកែប្រែជាបន្តបន្ទាប់នូវការរចនាក្រដាសប្រាក់ និងតម្លៃដោយភ្ជាប់ជាមួយលោហធាតុរហូតដល់ការត្រួតពិនិត្យរូបិយបណ្ណត្រូវបានអនុម័តជាផ្លូវការជាមួយច្បាប់សហព័ន្ធឆ្នាំ១៩១៣។ បន្ទាប់ពីការធ្វើកំណែទម្រង់នេះប្រាក់ដុល្លារ គឺជារូបិយបណ្ណបម្រុងរបស់ធនាគារកណ្តាលដែលអាចប្តូរយកបានតាមតម្លៃសមមូលទៅនឹងលោហធាតុនៅធនាគារណាមួយរបស់ធនាគារកណ្តាលអាមេរិក។

នៅឆ្នាំ១៩៣៣ ប្រធានាធិបតី Franklin D. Roosevelt បានហាមឃាត់ការរក្សាទុកមាសជាកម្មសិទ្ធិឯកជនដោយប្រជាជនត្រូវប្តូរមាសទាំងអស់ទៅជាប្រាក់ដុល្លារ។ នៅឆ្នាំ១៩៤៤គេបានបង្កើតកិច្ចព្រមព្រៀង Bretton Woods ដែលមាសគឺជាមូលដ្ឋានគ្រឹះនៃតម្លៃប្រាក់ដុល្លារអាមេរិកហើយរូបិយបណ្ណផ្សេងទៀតត្រូវបានកំណត់ជាប្រាក់ដុល្លារដោយអត្រាថេរ។

---

[1] https://www.sangapac.com/dictionary/pha/3733
[2] https://www.kampucheathmey.com/business-economic/529638
[3] https://corporatefinanceinstitute.com/resources/economics/dollarization/
[4] https://www.khsearch.com/qna/27047
[5] https://www.thebalancemoney.com/what-is-dollarization-5214456




រូបិយបណ្ណសំខាន់ៗទាំងអស់លើពិភពលោកផ្លាស់ប្តូរពីប្រព័ន្ធតម្លៃដែលមានមូលដ្ឋានលើលោហធាតុទៅជាអត្រាប្តូរប្រាក់ថេរដោយគេលក់មាសទៅឱ្យសហរដ្ឋអាមេរិកក្នុងតម្លៃ ៣៥ ដុល្លារក្នុងមួយអោនហើយត្រូវបង់ជាដុល្លារអាមេរិក។ ស្តង់ដារមាសនេះដែលជាការភ្ជាប់តម្លៃរូបិយបណ្ណទៅនិងតម្លៃមាសត្រូវបានគេឈប់ប្រើប្រាស់ជាផ្លូវការនៅឆ្នាំ១៩៧១ នៅពេលដែលប្រធានាធិបតី Richard M. Nixon បានប្រកាសថាអាមេរិកនិងមិនប្តូរមាសជារូបិយបណ្ណអាមេរិកទៀតទេហើយប្រព័ន្ធ Bretton Woods ត្រូវបានបញ្ចប់។ សព្វថ្ងៃនេះ USD គឺជារូបិយបណ្ណសេរីនៅលើទីផ្សារជួញដូររូបិយបណ្ណសកល។ ប្រាក់ដុល្លារអាមេរិកដើរតួជារូបិយបណ្ណបម្រុងរបស់ប្រទេសភាគច្រើនដែលជំនួសឱ្យការស្តុកទុកមាស និងប្រាក់ធនាគារកណ្តាលជុំវិញពិភពលោករក្សាទុនបំរុងជាប្រាក់ដុល្លារសម្រាប់ជាការការពារអតិផរណា។ យោងតាមធនាគារកណ្តាលគិតត្រឹមខែកក្កដា ឆ្នាំ ២០២១ មានរូបិយបណ្ណដុល្លារដែលកំពុងចរាចរមានជាង ២ ទ្រីលានដុល្លារ។ ចំនួននេះកើនឡើងដល់ជាង ២០,៤ ទ្រីលានដុល្លារប្រសិនបើគេគិតទាំងវង្វាស់ M2 នៃការផ្គត់ផ្គង់ប្រាក់ដែលរួមមានទ្រព្យមិនមែនសាច់ប្រាក់ដូចជាឧបករណ៍ទីផ្សារប្រាក់បញ្ញើ និងប្រាក់កម្ចីផ្សេងៗទៀត[6]។

#### ២.១.៣ ទ្រឹស្តីនៃដុល្លាររូបនីយកម្ម

ទ្រឹស្តី **ដុល្លារូបនីយកម្ម** គឺជាការចាប់យករូបិយបណ្ណរបស់បរទេសណាមួយសម្រាប់ធ្វើការទូទាត់ស្របច្បាប់នៅក្នុងប្រតិបត្តិការរូបិយវត្ថុ[7]។

លោក Kurt Schuler បាននិយាយថា**ដុល្លារូបនីយកម្ម** គឺជាបាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយ បានជ្រើសរើសប្រើប្រាស់ប្រាក់ដុល្លារអាមេរិក ឬរូបិយបណ្ណបរទេសដទៃទៀតជំនួសឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ[8]។

### ២.២ ផលប៉ះពាល់ដុល្លារូបនីយកម្មផ្តល់គុណសម្បត្តិ និងគុណវិបត្តិមកលើសេដ្ឋកិច្ច

#### ២.២.១ និយមន័យ

**សេដ្ឋកិច្ច** គឺជាសំណុំនៃទំនាក់ទំនងផលិតកម្ម ការប្រើប្រាស់ ការដោះដូរ និងការប្រើប្រាស់បែងចែកធនធានក្នុងសង្គម និងជាពិសេសអត្ថន័យសេដ្ឋកិច្ចគឺជាខឿននៃទំនាក់ទំនងនេះ[9]។

[6] https://economy.ams.com.kh/43671
[7] https://www.khsearch.com/qna/27047
[8] https://corporatefinanceinstitute.com/resources/economics/dollarization/
[9] https://web.facebook.com/story.php?story_fbid=2444569705869689&id=2219692831690712&rdid=dtDa6SjoPN856B19

**សេដ្ឋកិច្ច** គឺជាសិល្បៈដ៏ប្រសើរក្នុងការចាត់ចែងចំណូល និងចំណាយនៅក្នុងគ្រួសារការចាយវាយនិងរកចំណូលមកវិញតាមប្រសព្វនៃថវិកាសម្បត្តិទ្រព្យបេតិកភណ្ឌរបស់បុគ្គលណាម្នាក់ ឬរដ្ឋរបស់ប្រទេសណាមួយ[10] ។

**សេដ្ឋកិច្ច** ជាការសិក្សាពីរបៀបដែលបុគ្គលគ្រួសារសង្គមចេះលៃលកប្រើប្រាស់ នូវធនធានដែលមានក្នុងការផលិត ( ទំនិញនិងសេវាកម្ម) ដើម្បីបម្រើសេចក្តីត្រូវការឥតព្រំដែនរបស់មនុស្ស[11] ។

**សេដ្ឋកិច្ច** គឺជាកិច្ចការដឹកនាំឧត្តុង្គឧត្តមថ្លៃថ្លា ឬក៏ជាកិច្ចការទាំងឡាយដែលធ្វើឱ្យប្រទេសជាតិរីកចំរើន [12]។

**សេដ្ឋកិច្ច** គឺជាការសិក្សារូបិយវត្ថុ មូលធន និងទ្រព្យសម្បត្តិ[13]។

**គុណសម្បត្តិ** គឺជាការបរិបូណ៌ដោយសេចក្តីបរិសុទ្ធ ការបរិបូណ៌ដោយសេចក្តីល្អ និងសេចក្តីដល់ព្រមដោយគុណ[14]។

**គុណវិបត្តិ** គឺជាការប្រាកចាកគុណ ឬការខ្វះសេចក្តីល្អនៅក្នុងវត្ថុមនុស្ស ឬសកម្មភាព[15]។

**២.២.២ ប្រវត្តិនៃសេដ្ឋកិច្ចពិភពលោក**

នៅសម័យអន្តរកាលប្រវត្តិសាស្ត្រសេដ្ឋកិច្ចនឹងពង្រីកបន្ថែមទៀត ទោះជាយ៉ាងណាក៏ដោយវាបានផ្លាស់ប្តូរការផ្តោតអារម្មណ៍របស់ខ្លួនឆ្ពោះទៅរកបញ្ហាសេដ្ឋកិច្ចដែលកើតចេញពីសង្គ្រាមដូចជាសង្គ្រាម និងអតិផរណាក្រោយសង្គ្រាមឬឆ្ពោះទៅរកបញ្ហាដែលក្លាយជាបញ្ហាសំខាន់ក្នុងកំឡុងទសវត្សរ៍ទី30 ដូចជាភាពចលាចលដែលបណ្តាលមកពីវិបត្តិពិភពលោក។ តាមទស្សនៈរបស់អ្នកប្រវត្តិសាស្ត្រសេដ្ឋកិច្ចការប្រើប្រាស់ស្ថិតិប្រវត្តិសាស្ត្រអាចជួយយ៉ាងសំខាន់ក្នុងការធ្វើឱ្យការវិភាគកាន់តែស៊ីជម្រៅនៅក្នុងករណីទាំងពីរ។ គណៈកម្មាធិការវិទ្យាសាស្ត្រអន្តរជាតិសម្រាប់ប្រវត្តិសាស្ត្រតម្លៃត្រូវបានបង្កើតឡើងក្នុងឆ្នាំ1931 តាមគំនិតផ្តួចផ្តើមរបស់ Edwin F. Gay (អ្នកស្នងតំណែងរបស់ Ashley ក្នុងឆ្នាំ1902) និង William H. Beveridge (1879–1963) ដើម្បីកំណត់ក្នុងការសិក្សាតម្លៃដោយដៃនៅក្នុងប្រទេសអង់គ្លេស បារាំង អាល្លឺម៉ង់ អូទ្រីស ហូឡង់ សហរដ្ឋអាមេរិក អេស្ប៉ាញ និងប៉ូឡូញ។ ចាប់ពីឆ្នាំ1934តទៅការសិក្សាតម្លៃជាច្រើនទាក់ទងនិងប្រទេសទាំងនេះត្រូវបានបោះពុម្ពផ្សាយ។ បន្ទាប់ពីសង្គ្រាមលោកលើកទី2គណៈកម្មាធិការនឹងមិនសកម្មទៀតទេ ប៉ុន្តែការបោះពុម្ពផ្សាយនៃស៊េរីតម្លៃប្រវត្តិសាស្ត្រ នៅតែកើនឡើងមិនត្រឹមតែនៅក្នុងប្រទេសដែលបានរៀបរាប់ខាងលើប៉ុណ្ណោះទេប៉ុន្តែក៏មាននៅក្នុងប្រទេសបែលហ្សិក ដាណឺម៉ាក រុស្ស៊ី អ៊ីតាលី និងប្រទេសជាច្រើនទៀតផងដែរ។

នៅប្រទេសបារាំងការសាងសង់ស៊េរីតម្លៃរយៈពេលវែងមានគោលបំណងដើមដំបូងដើម្បីផ្ទៀងផ្ទាត់ ឬក្លែងបន្លំទ្រឹស្តីរូបិយវត្ថុបរិមាណ។ François Simiand (1873–1935) គឺជាអ្នកត្រួសត្រាយផ្លូវក្នុងរឿងនេះ ប៉ុន្តែគាត់បានពង្រីកការស្រាវជ្រាវរបស់គាត់ ដើម្បីស្វែងរកផងដែរនូវតួនាទីនៃប្រាក់ឈ្នួលនៅក្នុងសេដ្ឋកិច្ចដោយផ្អែកវាម្តងទៀតលើស្ថិតិប្រវត្តិសាស្ត្រ។ Ernest Labrousse (1895-1989) បានកាន់កាប់កេរដំណែលរបស់ Simiand

[10] https://www.khsearch.com/qna/8338
[11] https://www.khsearch.com/qna/22672
[12] https://km.wikipedia.org/wiki/
[13] https://www.khsearch.com/qna/14292
[14] https://www.youtube.com/watch?v=1Ju2LtPuIGA
[15] https://www.sangapac.com/dictionary/ko/915

ទោះជាយ៉ាងណាក៏ដោយតម្រង់វាឆ្ពោះទៅរកការវិភាគនៃការប្រែប្រួលនៃវដ្តនៅអឺរ៉ុបក្នុងកំឡុងរបបAncian។ សេដ្ឋវិទូ និងអ្នកប្រវត្តិសាស្ត្រសេដ្ឋកិច្ចជាពិសេសនៅក្នុងបណ្តាប្រទេស Anglo-Saxon មានការចាប់អារម្មណ៍ច្រើនក្នុងការសិក្សាអំពីវដ្តអាជីវកម្ម 'ទំនើប' ។ ក្រៅពីការបង្កើតគណកម្មាធិការអន្តរជាតិស្តីពីប្រវត្តិសាស្ត្រតម្លៃ ការផ្តួចផ្តើមគំនិតច្នៃប្រឌិតសំខាន់ៗចំនួនពីរទៀតត្រូវបានគេធ្វើឡើងក្នុងអំឡុងពេលអន្តរបញ្ចរដែលដូចទៅនឹងប្រវត្តិតម្លៃផងដែរ និងបន្តមានឥទ្ធិពលលើប្រវត្តិសាស្ត្រសេដ្ឋកិច្ចក្រោយសង្គ្រាមយ៉ាងសំខាន់ ជាដំបូងដែលត្រូវនិយាយ គឺគម្រោងមហិច្ឆតានៃការបោះពុម្ពផ្សាយពហុភាគនៃ Cambridge Economic History of Europe ដែលសរសេរដោយក្រុមអ្នកប្រាជ្ញអន្តរជាតិដ៏ធំដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ភាគដំបូងបានបង្ហាញខ្លួននៅឆ្នាំ1941 ហើយត្រូវបានបន្តដោយអ្នកផ្សេងទៀតជាច្រើន។ ការបង្កើតនៅឆ្នាំ1929 នៃទស្សនាវដ្តីបារាំង Annales d'histoire économique et sociale ដោយ Marc Bloch (1886–1944) និង Lucien Febvre (1878–1956) គឺជាព្រឹត្តិការណ៍សំខាន់ទីពីរ។ ស្ថាបនិកទាំងពីរមានមហិច្ឆតាក្នុងការលើកទឹកចិត្តប្រភេទថ្មីនៃប្រវត្តិសាស្ត្រសង្គម និងសេដ្ឋកិច្ចដោយផ្តោតលើជីវិតសម្ភារៈប្រចាំថ្ងៃ និងធ្វើឱ្យប្រវត្តិសាស្ត្រប្រភេទនេះពិតជាអន្តរកម្មដោយការរួមបញ្ចូលវិទ្យាសាស្ត្រសង្គម។

ការទទួលស្គាល់ប្រវត្តិសាស្ត្រសេដ្ឋកិច្ចជាប្រធានបទដាច់ដោយឡែក គឺអាចតាមដានបានចំពោះការបង្រួបបង្រួមនៃសេដ្ឋកិច្ច neoclassical របស់អង់គ្លេសនៅវេននៃសតវត្សទី20 ក្រោមឥទ្ធិពលដ៏ខ្លាំងរបស់ Alfred Marshall និងអ្នកស្នងតំណែង Cambridge របស់គាត់ A.C. Pigou ។ ស្នូលនៃការវិភាគនៃសាលាដែលលេចធ្លោបានចាត់ទុកថាសេដ្ឋកិច្ចមានទំនោរទៅរក 'លំនឹងរយៈពេលវែង' ដែលមិនអាស្រ័យលើលក្ខខណ្ឌដំបូង (ទោះបីជាលោក Marshall ខ្លួនគាត់ផ្ទាល់មិនមានការសង្ស័យអំពីគោលលទ្ធិនេះក្នុងការអនុវត្តក៏ដោយ)។ ដោយបានបាត់បង់នៅក្នុងការតស៊ូដើម្បីអត្តសញ្ញាណវិន័យនៃសេដ្ឋកិច្ចខ្លួនវា 'សាលាប្រវត្តិសាស្ត្រនៃសេដ្ឋកិច្ច' បានលេចឡើងនៅពេលនោះជាប្រតិកម្មប្រឆាំងនឹងគំរូ neoclassical និងកម្មវិធី laissez-faire ដែលវាត្រូវបានផ្សារភ្ជាប់។ ដោយបានគូរគំនិត និងការបំផុសគំនិតពី 'សាលាប្រវត្តិសាស្ត្រអាឡឺម៉ង់' របស់ Gustav Schmoller និង Friedrich List អ្នកសេដ្ឋកិច្ចប្រវត្តិសាស្ត្រដំបូងបានសង្កត់ធ្ងន់លើគុណធម៌នៃការសិក្សាប្រឌិតដែលផ្ទុយពីវិធីសាស្ត្រដកយក ឬ axiomatic។ ការរៀបចំប្រវត្តិសាស្ត្រសេដ្ឋកិច្ចជាវិស័យសិក្សានៅប្រទេសអង់គ្លេសត្រូវបានជំរុញឱ្យមានការស្វែងរកកន្លែងជ្រកកោនដូចជាការលេចចេញនូវរបៀបស្រាវជ្រាវប្លែកៗ។ លោកWilliam James Ashley ប្រធានទីមួយនៃសង្គមប្រវត្តិសាស្ត្រសេដ្ឋកិច្ចបង្កើតឡើងរបស់ខ្លួនក្នុងឆ្នាំ1926 បានទួញសោកថា៖ អ្នកសេដ្ឋកិច្ចតាមទ្រឹស្តីបានត្រៀមខ្លួនរួចជាស្រេចដើម្បីរក្សាយើងឱ្យនៅស្ងៀម ដោយផ្តល់ឱ្យយើងនូវគម្រោងសួនច្បារដែលមិនមានជម្លោះតិចតួចសម្រាប់យើង។ ហើយយើងជាអ្នកប្រវត្តិសាស្ត្រដែលបន្ទាបខ្លួនមានអំណរគុណយ៉ាងខ្លាំងចំពោះទឹកដីដែលមិនមានជម្លោះតិចតួច ដែលយើងមានទំនោរចង់ទុកអ្នកសេដ្ឋកិច្ចទៅឧបករណ៍របស់ពួកគេផ្ទាល់ ភាពតានតឹងស្រដៀងគ្នានេះបានបន្តកើតមានក្នុងសហរដ្ឋអាមេរិក ប៉ុន្តែការបំបែករវាងសេដ្ឋកិច្ច និងប្រវត្តិសេដ្ឋកិច្ចមានការអភិវឌ្ឍយឺតជាង។ វិធីសាស្ត្រណែនាំនៃសាលា 'ស្ថាប័ន' ដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងតួរលេខដូចជា John R. Commons និង Thorstein Veblen មានភាពលេចធ្លោនៅក្នុងសេដ្ឋ

កិច្ចការងារ និងនៅក្នុងផ្នែកផ្សេងទៀតនៃវិន័យមាតាបិតាដែលផ្លាស់ប្តូរទីលំនៅដោយការកើនឡើងនៃសេដ្ឋកិច្ច Keynesian ក្នុងទសវត្សរ៍ឆ្នាំ1930 និងឆ្នាំ1940 ប៉ុណ្ណោះ។ នៅក្នុងយុគសម័យដូចគ្នាប្រវត្តិវិទូ 'ជឿនលឿន' ដូចជា Frederick Jackson Turner និង Charles Beard បានដាក់ជម្លោះសេដ្ឋកិច្ច និងការផ្លាស់ប្តូរនៅចំកណ្តាលនៃ 'ការបកស្រាយសេដ្ឋកិច្ចនៃប្រវត្តិសាស្ត្រ' របស់ពួកគេ។ ទោះបីជាក្រុមទាំងពីរនេះមិនត្រូវបានទទួលស្គាល់ថាជាអ្នកប្រវត្តិសាស្ត្រសេដ្ឋកិច្ចនាពេលបច្ចុប្បន្ននេះក៏ដោយពួកគេបានផ្តល់នូវច្រកចេញសម្រាប់អ្នកដែលមិនពេញចិត្តជាមួយនឹងវិធីសាស្ត្រនៃវិធីសាស្ត្រដកប្រាក់។ ដូច្នេះសមាគមប្រវត្តិសាស្ត្រសេដ្ឋកិច្ច (អាមេរិក) ត្រូវបានបង្កើតឡើងតែនៅក្នុងឆ្នាំ1940 ហើយខ្វះអត្តសញ្ញាណមនោគមវិជ្ជា និងភាពក្លៀវក្លារបស់ភាគីអង់គ្លេស។

នៅចន្លោះទសវត្សរ៍ឆ្នាំ1930 និងឆ្នាំ1950 តួលេខពិសេសមួយចំនួនដូចជា Carter Goodrich អាចមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសេដ្ឋកិច្ច និងប្រវត្តិសាស្ត្រសេដ្ឋកិច្ច។ ប៉ុន្តែសមាជិកភាគច្រើននៃសមាគមប្រវត្តិសាស្ត្រសេដ្ឋកិច្ច (EHA) គឺជាអ្នកប្រវត្តិសាស្ត្រដែលស្នាដៃរបស់ពួកគេបានប្រើប្រាស់សេដ្ឋកិច្ចតិចតួច និងមានឥទ្ធិពលតិចតួចលើការគិតរបស់អ្នកសេដ្ឋកិច្ច ដូចគ្នានេះដែរអាចនិយាយបានថាសម្រាប់ប្រវត្តិសាស្ត្រសហគ្រិនដែលរីកដុះដាលអស់មួយរយៈនៅមជ្ឈមណ្ឌល Harvard Center for Entrepreneurial History ក្រោមការដឹកនាំរបស់ Arthur H. Cole ។ រំលឹកឡើងវិញការសិក្សាពិពណ៌នាដ៏សម្បូរបែបជាច្រើនពីសម័យនេះមានតម្លៃយូរអង្វែងប្រហែលជាត្រូវបានឆ្លុះបញ្ចាំងយ៉ាងល្អបំផុតនៅក្នុងស៊េរី Monographic ដែលមានចំណងជើងថា The Economic History of the United States ដែលបានបោះពុម្ពនៅចន្លោះឆ្នាំ1945 និង 1962។ ប៉ុន្តែដោយសារសេដ្ឋកិច្ចបានក្លាយទៅជាការវិភាគ និងបរិមាណកាន់តែខ្លាំងប្រវត្តិសាស្ត្រសេដ្ឋកិច្ចនៅពេលវេលាហាក់ដូចជាអ្វីមួយនៃការត្រឡប់មកវិញដ៏រឹងមាំ[16]។

**២.២.៣ ទ្រឹស្តីនៃសេដ្ឋកិច្ច**

**លោក Adam Smith បាននិយាយថាសេដ្ឋកិច្ច** គឺជាការសិក្សាអំពីធម្មជាតិ និងហេតុផលផ្សេងៗនៃទ្រព្យសម្បត្តិ។

**លោក Alfred Marshall បាននិយាយថាសេដ្ឋកិច្ច** គឺជាការសិក្សានូវរាល់សកម្មភាពរបស់មនុស្សដែលធ្វើឡើយដើម្បីទទួលបាននូវសុខុមាលភាពសេដ្ឋកិច្ច។

**តាមទ្រឹស្តីបច្ចុប្បន្ន សេដ្ឋកិច្ច** គឺជាការសិក្សាអំពីការបែងចែកធនធានកម្រ ដើម្បីបំពេញនូវតម្រូវការគ្មានព្រំដែលរបស់មនុស្ស ឬជាការសិក្សាអំពីឥរិយាបថរបស់មនុស្សដែលទាក់ទង និងការជ្រើសរើសយករបៀបណាមួយនៅក្នុងការផលិត ការចែកចាយ ការប្រើប្រាស់វត្ថុធាតុដើម និងការប្រើប្រាស់សេវាកម្មក្នុងប្រភពនៃធនធានកម្រ[17]។

**សេដ្ឋកិច្ច** ជាទស្សនទានចង្អុលបង្ហាញពីគោលការណ៍តម្រង់ដំណើរជីវិតរបស់ប្រជាជនគ្រប់ជាន់ថ្នាក់ រាប់តាំងពីកម្រិតគ្រួសារកម្រិតសហគមន៍រហូតដល់កម្រិតថ្នាក់ជាតិទាំងក្នុងការអភិវឌ្ឍ និងគ្រប់គ្រងប្រទេសឱ្យឈានទៅរកផ្លូវកណ្តាលជាពិសេសការអភិវឌ្ឍសេដ្ឋកិច្ចដើម្បីដើរឱ្យដល់សកលភាវូបនីយកម្ម។ ភាពគ្រប់

[16] https://www.sciencedirect.com/topics/social-sciences/economic-history

[17] https://www.youtube.com/watch

គ្រាន់សំដៅលើភាពសមរម្យភាពមានហេតុផលរួមទាំងភាពចាំបាច់ដែលតម្រូវឱ្យមាន ប្រព័ន្ធការពារក្នុងខ្លួន ដែលល្អសមរម្យចំពោះផលប៉ះពាល់ផ្សេងៗដែលបានកើតឡើងពីការផ្លាស់ប្តូរទាំងខាងក្នុង និងខាងក្រៅទាំងអស់នេះអ្នកត្រូវពឹងលើចំណេះដឹង ភាពសព្វគ្រប់ជ្រៅជ្រះ និងភាពប្រយ័ត្នប្រយែងយ៉ាងខ្លាំងក្នុងការនាំយកចំណេះដឹងផ្សេងៗមកប្រើក្នុងការធ្វើផែនការ និងការអនុវត្តគ្រប់ដំណាក់កាល។ ទ្រឹស្តីសេដ្ឋកិច្ច គឺជាវិធីសាស្ត្រមួយចំពោះសេដ្ឋកិច្ចផ្តោតលើការប្តេជ្ញាចិត្ត ទំនិញ ផលិតផល និងការបែងចែកប្រាក់ចំណូលនៅលើទីផ្សារតាមរយៈការផ្គត់ផ្គង់ និងតម្រូវការ[18]។

## ២.៣ គោលនយោបាយរូបិយវត្ថុរបស់ធនាគារដើម្បីគ្រប់គ្រងដុល្លារូបនីយកម្ម

### ២.៣.១ និយមន័យ

**គោលនយោបាយរូបិយវត្ថុ** គឺជាសំណុំនៃឧបករណ៍ដែលប្រើប្រាស់ដោយធនាគារកណ្តាលរបស់ប្រទេសមួយដើម្បីគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់ទាំងមូល និងលើកកម្ពស់កំណើនសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់យុទ្ធសាស្ត្រដូចជាកែសម្រួលអត្រាការប្រាក់ និងការផ្លាស់ប្តូរតម្រូវការទុនបម្រុងធនាគារជាដើម[19]។

**គោលនយោបាយរូបិយវត្ថុ** គឺជាឧបករណ៍មួយប្រភេទរបស់នយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលមានខ្លឹមសារទាក់ទងនឹងការគ្រប់គ្រង ការផ្គត់ផ្គង់រូបិយវត្ថុ និងឥណទានគិតជាចំនួនសរុបក្នុងប្រព័ន្ធហិរញ្ញវត្ថុ គឺសំដៅលើការព្យាយាមរក្សាលំនឹងសេដ្ឋកិច្ចឱ្យមានដំណើរផលិតកម្មពេញលេញ និងគ្មានអតិផរណា[20]។

**គោលនយោបាយរូបិយវត្ថុ** គឺជាដំណើរការដែលអាជ្ញាធររូបិយវត្ថុនៃប្រទេសមួយគ្រប់គ្រងលើការផ្គត់ផ្គង់រូបិយវត្ថុ ដោយការកំណត់អត្រាការប្រាក់សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចនិងស្ថិរភាព[21]។

**ធនាគារ** គឺជាស្ថានប័នហិរញ្ញវត្ថុដែលបើកសេវាធំទូលាយជាងស្ថាប័នហិរញ្ញវត្ថុដទៃទៀត។ វាបានដើរតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការអន្តរការី រវាងអ្នកត្រូវមានមូលធន ឬអ្នកខ្ចីប្រាក់ និងអ្នកដែលមានមូលធនលើសផ្ញើប្រាក់នូវធនាគារ។ ធនាគារបានបំពេញតួនាទីជាស្ថាប័នហិរញ្ញវត្ថុនៅពេលដែលមានធនាគារផ្ទេរប្រាក់ដែលបានមកពីការផ្ញើរបស់អតិថិជន ឬអង្គភាពពាណិជ្ជកម្មឱ្យអ្នកដទៃមានតម្រូវការមូលធន ឬតម្រូវការវិនិយោគ។

**ធនាគារ** មានន័យថាជាឃ្លាំងទ្រព្យ ឃ្លាំងទុកដាក់ប្រាក់កាក់។ តាមនិយមន័យសេដ្ឋកិច្ចធនាគារគឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលធ្វើប្រតិបត្តការផ្នែកសេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទមាន ដូចជាការទទួលប្រាក់បញ្ញើសន្សំពីសាធារណជន ផ្តល់ឥណទានឯកជន ផ្តល់ឥណទានដល់ឯកត្តជន និងក្រុមហ៊ុនអាជីវកម្មដោយយកការប្រាក់ ផ្តល់សេវាទូទាត់ និងសេវាកម្មហិរញ្ញវត្ថុទៀត ហើយក៏ជាអ្នកវិនិយោគលើមូលបត្រមានតម្លៃដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ម្ចាស់ភាគហ៊ុន[22]។

**ការគ្រប់គ្រង** គឺជាដំណើរការនៃការប្រើប្រាស់ធនធាននៅក្នុងអង្គភាពអោយទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[23]។

[18] សារណារៀមច្បងជំនាន់ទី១៨ ការជួញដូរមូលបត្រនៅកម្ពុជា ទំព័រទី៧
[19] https://thmeythmey.com/
[20] https://www.khsearch.com/
[21] https://www.khsearch.com/
[22] សារណារៀមច្បងជំនាន់ទី១៧ ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទំព័រទី៥
[23] https://www.khsearch.com/qna/24819

**ការគ្រប់គ្រង** គឺជាដំណើរការរៀបចំចាត់តែងដឹកនាំ និងត្រួតពិនិត្យដោយប្រើធនធានផ្សេងៗទៀតដើម្បីសម្រេចគោលដៅ[24] ។

**២.៣.២ ប្រវត្តិ**

**ក. ប្រវត្តិនៃការកកើតធនាគារ**

ប្រវត្តិនៃការកកើតធនាគារ គឺជាការផ្សាភ្ជាប់ជាមួយនឹងការរីកចម្រើនវិស័យហផលិតកម្ម។ ដំណើរការនៃការភិវឌ្ឍសេដ្ឋកិកច្ច គឺជាលក្ខខណ្ឌនិងការទាមទារការអភិវឌ្ឍរបស់ធនាគាររហូតមកដល់បច្ចុប្បន្ននេះការអភិវឌ្ឍប្រព័ន្ធធនាគារបានជម្រុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។

ធនាគារចាប់ផ្តើមបង្កើតឡើងតាមរយៈមុខងារប្តូរលុយរបស់ជាងមាស ចំពោះការចរាចរណ៍លុយនៅក្នុងប្រទេសនីមួយៗក្នុងតំបន់នីមួយៗ ជាពិសេសចំពោះពាណិជ្ជកម្មអន្តរជាតិទាមទារឱ្យមានការប្តូរប្រាក់នៅតាមច្រកព្រំដែនដើម្បីងាយស្រួលក្នុងការទិញលក់ទំនិញ ដូចនេះត្រូវបានបង្កើតឡើងនូវហាងប្តូរប្រាក់ដើម្បីធ្វើការដោះដូរនូវរូបិយបណ្ណរបស់ប្រទេសនីមួយៗនិងរូបិយបណ្ណរបស់ប្រទេសមួយទៀត។ ចំពោះអ្នកដែលរកស៊ីប្តូរប្រាក់នេះភាគច្រើនជាអ្នកមាន និងពីមុនជាអ្នកអាចផ្តល់កម្ចីដោយយកប្រាក់ជាច្រើន ឬរក្សាប្រាក់ឱ្យអ្នកធ្វើអាជីវកម្មផ្សេងៗដូចនេះពួកគេកាន់តែមានចំណូលខ្ពស់ថែមទៀត។ ម្យ៉ាងទៀតការរក្សាលុយទុកកាន់តែច្រើនឡើងៗធ្វើឱ្យមានការទូទាត់ថ្លៃទំនិញច្រើនឡើងថែមទៀត ឬការទូទាត់មិនប្រើសាច់ប្រាក់។ តាមរយៈការទូទាត់មិនប្រើសាច់ប្រាក់នេះបានធ្វើឱ្យពាណិជ្ជករផ្ញើប្រាក់កាន់តែច្រើនឡើងថែមទៀត។

ដោយសារការប្រើប្រាស់លោហៈធាតុ (ដូចជាប្រាក់ ឬមាស) ម្ចាស់ហាងមានតួនាទីជាអ្នកប្តូរប្រាក់ និងទូទាត់ជំនួសរក្សាទុកឱ្យ និងផលិតលុយ។ ធនាគារប្រភេទនេះគេហៅថាធនាគាររបស់ជាងមាស។ មុខរបររបស់ធនាគារក៏ចាប់ផ្តើមពីអ្នកផ្តល់កម្ចីដោយយកប្រាក់ជាច្រើន ព្រោះអ្នកផ្តល់កម្ចីនេះបានអនុវត្តមុខងារប្តូរប្រាក់រក្សាទុក និងទូទាត់ជំនួស។

ដំបូងបណ្តាធនាគារទាំងនេះបានប្រើប្រាស់នូវមូលធនផ្ទាល់ខ្លួនក្នុងប្រតិបត្តិការរបស់ខ្លួន។ប៉ុន្តែកត្តានេះមិនអាចស្ថិតស្ថេរជាយូរអង្វែងនោះទេ តាមរយៈប្រតិបត្តិការជាក់ស្តែងម្ចាស់ធនាគារយល់ឃើញថាជានិច្ចកាលមានអ្នកផ្ញើលុយ និងអ្នកសុំខ្ចីលុយ។ ម្យ៉ាងទៀតមានអ្នកផ្ញើលុយសល់នៅធនាគារច្រើនដូចនេះម្ចាស់ធនាគារក៏ប្រើប្រាស់លុយទាំងនេះដើម្បីផ្តល់នូវកម្ចីបន្ថែម។ ប្រតិបត្តិការផ្តល់កម្ចីបានបង្កើតប្រាក់ចំណេញយ៉ាងច្រើនដល់ធនាគារដូចនេះធនាគារត្រូវស្វែងរកដំណោះស្រាយដែលអាចឱ្យប្រមូលប្រាក់បញ្ញើកាន់តែច្រើនឡើងៗដើម្បីផ្តល់កម្ចី។ ដូចនេះធនាគារបានផ្តល់ប្រាក់បញ្ញើរបស់អ្នកផ្ញើលុយ ម្យ៉ាងទៀតដើម្បីឱ្យការផ្តល់កើនឡើងឱ្យបានសមស្របទៅ និងប្រាក់បញ្ញើដែលបានកើតឡើងនេះធនាគារបានបន្ទាបការប្រាក់កម្ចី។ ក្នុងពេលនោះម្ចាស់ធនាគារធំៗមួយចំនួនបានពង្រីកការផ្តល់កម្ចីក្នុងគោលបំណងជាជំនួយដល់ការធ្វើសឹកសង្គ្រាមផ្សេងៗ។ ម្យ៉ាងទៀតធនាគារបានផ្តល់កម្ចីមួយប្រភេទមានន័យថាអនុញ្ញាតឱ្យចាយលុយលើសពីប្របញ្ញើរបស់ខ្លួនការផ្តល់កម្ចីនេះ គឺមានហានិភ័យខ្ពស់។ ប៉ុន្តែដោយសារប្រាក់ចំណេញពីការផ្តល់កម្ចីមានកម្រិតខ្ពស់បានធ្វើឱ្យធនាគារជាច្រើនប្រើប្រាស់នូវលិខិតបញ្ជាក់ប្រាក់បញ្ញើ (ជំនួសឱ្យមានការចរាចរមាស ឬប្រាក់) និងបោះពុម្ពលិខិតផ្តល់កម្ចី។ ស្ថានភាពទាំងនេះបានធ្វើឱ្យធនាគារជាច្រើនគ្មានសមត្ថភាពសង និងក្ស័យធុន។

[24] https://www.khsearch.com/

ការក្ស័យធុនរបស់ធនាគារទាំងនោះបានធ្វើឱ្យការទូទាត់ជំនួសជូននូវវិបត្តិធ្ងន់ធ្ងរ និងជះឥទ្ធិពលអាក្រក់ដល់អ្នកធ្វើអាជីវកម្ម។ ម្យ៉ាងទៀតអត្រាការប្រាក់ខ្ពស់ធ្វើឱ្យគេទទួលយកមិនបានដូចនេះពួកគេក៏បង្កើតធនាគារដោយខ្លួនឯងដែលហៅថាធនាគារពាណិជ្ជ។ ធនាគារពាណិជ្ជបានបង្កើតឡើងដោយពាណិជ្ជករ ធនាគារនេះបានអនុវត្តដូចជាធនាការមុនដែរ គឺទទួលប្រាក់បញ្ញើ រក្សាទុក ទទូទាត់ជំនួស និងផ្តល់កម្ចីដើម្បីទប់ស្កាត់ហានិភ័យធនាគារនេះគ្រាន់តែផ្តល់កម្ចីរយៈពេលខ្លីតែប៉ុណ្ណោះគឺមិនផ្តល់កម្ចីរយៈពេលវែង និងមធ្យមទេម្យ៉ាងទៀតមិនផ្តល់កម្ចីដល់អ្នកប្រើប្រាស់ និងរដ្ឋាភិបាលទេ។

ការក្ស័យធុនរបស់ធនាគារជាច្រើនបានធ្វើឱ្យអ្នកខ្ចីលុយទទួលរងការខាតបង់យ៉ាងធ្ងន់ធ្ងរ និងជាមូលហេតុបង្កើតឱ្យមានឡើងនូវធនាគារទទួលប្រាក់បញ្ញើមានន័យថាធនាគារមិនផ្តល់កម្ចីទេ គឺគ្រាន់តែរក្សាលុយជំនួស និងទូទាត់ជំនួយដោយយកសេវាប៉ុណ្ណោះ។ ស្របពេលនេះដែរនៅតាមបណ្តាប្រទេសនីមួយៗបានបង្កើតឡើងនូវធនាគារជាច្រើន ដូចជាធនាគារឯកទេស ធនាគារអភិវឌ្ឍន៍ ធនាគារពាណិជ្ជ ធនាគារកណ្តាល។ល។ នេះជាបង្កើតឡើងនូវប្រព័ន្ធធនាការមួយ។

តាមរយៈការរីកចម្រើននៃផ្នែកសេដ្ឋកិច្ចបច្ចេសទេសបានធ្វើឱ្យប្រត្តិការរបស់ធនាគារកាន់តែរីកចម្រើនដែរ គឺតាំងពីធនាគារបុគ្គលរហូតដល់កើតឡើងធនាគារភាគហ៊ុន។ ក្រោយមកទៀតធនាគារពាណិជ្ជបានផ្តល់កម្ចីរយៈពេលវែងទៀត និងផ្តល់កម្ចីដល់អ្នកប្រើប្រាស់ អ្នកទិញប័ណ្ណភាគហ៊ុន និងបង្កើតឡើងនូវប្រភេទប្រាក់បញ្ញើជាច្រើន តាមតម្រូវការអតិថិជនក្រៅពីការទទួលប្រាក់បញ្ញើធនាគារនូវមានការសុំខ្ចីពីធនាគារកណ្តាល និងធនាគារផ្សេងទៀត[25]។

**ខ.ប្រវត្តិនៃការគ្រប់គ្រង**

គំនិតនៃការគ្រប់គ្រងមានតាំងពីរាប់ពាន់ឆ្នាំមកហើយ។ យោងទៅតាម Pindur, Rogers, និងKim (១៩៩៥) វិធីសាស្ត្រសំខាន់ៗក្នុងការគ្រប់គ្រងវិលត្រឡប់យ៉ាងហោចណាស់ ៣០០០ឆ្នាំ មុនពេលប្រសូតនៃព្រះគ្រីស្ទ ដែលជាពេលវេលាកំណត់ត្រានៃការធ្វើជំនួញត្រូវបានកត់ត្រាដោយពួកបូជាចារ្យនៅបដ្ឋិមបូព៌ា។ ប្រហែល ៤០០ មុនគ.ស បានថ្លែងថាការគ្រប់គ្រងគឺជាសមត្ថភាពខុសគ្នាដាច់ឆ្ងាយពីការមានជំនាញបច្ចេកទេស និងចំណេះដឹង (Higgins ឆ្នាំ១៩៩១)។ ជនជាតិរ៉ូមដែលល្បីល្បាញខាងកងពលដែលដឹកនាំដោយមេទ័ពផ្តល់ការទទួលខុសត្រូវតាមរយៈឋានានុក្រមនៃអំណាច។ ព្រះវិហាររ៉ូម៉ាំងកាតូលិកត្រូវបានរៀបចំឡើងតាមខ្សែបន្ទាត់នៃទឹកដីជាក់លាក់ខ្សែសង្វាក់ពាក្យបញ្ជា និងការពិពណ៌នាការងារ។ ក្នុងយុគសម័យមជ្ឈឹមរយៈពេល ១.០០០ ឆ្នាំចាប់ពីឆ្នាំ៤៧៦នៃគ.ស រហូតដល់ឆ្នាំ១៤៥០គ.ស។ Guildsដែលជាការប្រមូលផ្តុំនៃសិប្បករ និងពាណិជ្ជករដែលបានផ្គត់ផ្គង់ទំនិញធ្វើដោយដៃរាប់ចាប់ពីនំប៉័ងរហូតដល់គ្រឿងសឹកនិងដងាវសម្រាប់ធ្វើបូជនីយកិច្ច។ ឋានានុក្រមនៃការគ្រប់គ្រងអំណាចប្រហាក់ប្រហែលនិងព្រះវិហារកាតូលិកដែលមានអំណាចស្ថិតនៅជាមួយចៅហ្វាយនាយហើយបោកបញ្ឆោតដល់អ្នកធ្វើដំណើរ និងកូនជាង។ សិប្បករទាំងនេះជាអាជីវកម្មខ្នាតតូចដែលផលិតផលមានគុណភាពខុសៗគ្នា អត្រាផលិតភាពទាបនិងតម្រូវការតិចតួចសម្រាប់ការគ្រប់គ្រងដែលលើសពីម្ចាស់ឬសប្បករជំនាញ។ បដិវត្តឧស្សាហកម្មដែលជាពេលវេលាមួយពីចុងទសវត្សឆ្នាំ ១៧០០ រហូតដល់ទសវត្ស១៨០០ គឺជាសម័យកាលនៃការផ្លាស់ប្តូរដ៏ធំធេងនៃការផ្លាស់ប្តូរទ្រង់ទ្រាយធំនៅក្នុងរបៀបដែល

[25] សារណាវៀមច្បងជំនាន់ទី១៧ ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទំព័រទី៥-៧

ប្រជាជនរស់នៅ និងធ្វើការ។ មុនពេលនេះប្រជាជនភាគច្រើនប្រកបរបរកសិកម្មចិញ្ចឹមជីវិតឬធ្វើការហើយរស់នៅក្នុងសហគមន៍ជនបទ។ ការបង្កើតម៉ាស៊ីនចំហុយការបង្កើតថ្មីជាច្រើនបានកើតឡើងរួមមានចលនាស្វ័យប្រវត្តិធ្យូងថ្មពីអណ្តូងរ៉ែក្រោមដីរោងចក្រផ្តល់ថាមពលដែល ឥឡូវនេះទំនិញផលិតទ្រង់ទ្រាយធំផលិតដោយដៃផ្ទាល់ និងក្បាលរថភ្លើងផ្លូវដែកដែលអាចដឹកជញ្ជូនផលិតផលនិងវត្ថុធាតុដើមឆ្លងកាត់ប្រទេសនានាបានទាន់ពេលវេលា និងលក្ខណៈប្រសិទ្ធភាពរោងចក្រត្រូវការកម្មករដែលទាមទារទិសដៅនិងការរៀបចំ។ នៅពេលដែលគ្រឿងបរិក្ខារទាំងអស់នេះមានលក្ខណៈកាន់តែច្រើន និងមានផលិតភាពតម្រូវការសម្រាប់ការគ្រប់គ្រងនិងសម្របសម្រួលបានក្លាយជាកត្តាសំខាន់។ គិតអំពីហេនរីហ្វដបុរសម្នាក់ដែលបានបង្កើតខ្សែបណ្តាញផ្លាស់ប្តូរមួយដើម្បីផលិតរថយន្តរបស់គាត់។ នៅដើមទសវត្ស១៩០០ រថយន្តត្រូវបានដាក់បញ្ចូលគ្នាដោយសិប្បករដែល និងកែប្រែគ្រឿងបន្លាស់ឱ្យសមនិងផលិតផលរបស់ពួកគេ។ ការមកដល់នៃផ្នែកដែលមានលក្ខណៈស្តង់ដាក្នុងឆ្នាំ១៩០៨ បន្ទាប់មកខ្សែសង្វាក់បដិវត្តរបស់ក្រុមហ៊ុនហ្វដត្រូវបានណែនាំក្នុងឆ្នាំ១៩១៣ ពេលវេលាដែលត្រូវការដើម្បីផលិតម៉ូឌែល T បានធ្លាក់ចុះពីប៉ុន្មានថ្ងៃទៅប៉ុន្មានម៉ោងប៉ុណ្ណោះ (កាឡាស២០២០) តាមទស្សនៈរបស់អ្នកគ្រប់គ្រងសិប្បករជំនាញលែងចាំបាច់ក្នុងការផលិតឡានទៀតហើយ។ ការប្រើប្រាស់កម្លាំងពលកម្មដែលមានតម្លៃទាប និងការកើននៃការផលិតដែលជម្រុញដោយការផ្លាស់ប្តូរខ្សែសង្វាក់ផលិតកម្មបានអំពាវនាវឱ្យមានតម្រូវការណែនាំនិងគ្រប់គ្រងប្រតិបត្តិការដ៏ធំធេងទាំងនេះ (វីលសុនឆ្នាំ២០១៥) ដើម្បីទទួលបានអត្ថប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗវិធីសាស្ត្រផ្សេងចំពោះរចនាសម្ព័ន្ធ និងការគ្រប់គ្រងអង្គភាពត្រូវបានទាមទារ[26]។

### ២.៣.៣ ទ្រឹស្តីនៃធនាគារ

តាមប្រវត្តិសាស្ត្រ ជាធម្មតាធនាគាររងចាំអតិថិជនដើម្បីនាំយកលុយមកដាក់ធនាគារហើយ និងផ្តល់ឱ្យអតិថិជនវិញនូវប្រភេទគណនីណាមួយដែលគេចង់បាន ដូចជាគណនីចរន្ត គណនីសន្សំ គណនីមានកាលកំណត់...។

**ធនាគារ** គឺជាអន្តរការីហិរញ្ញវត្ថុដែលទទួលប្រាក់បញ្ញើ និងប្រើប្រាស់ដើម្បីទិញមូលបត្រ។ វាបង្ហាញពីការចូលរួមពីការគ្រប់គ្រងសាច់ប្រាក់នៅក្នុងសេដ្ឋកិច្ច តាមរយៈប្រាក់បញ្ញើ ឬសកម្មភាពរបស់ធនាគារដើម្បីទទួលបាននូវលំនឹងទូទៅដែលធានាបាននូវស្ថេរភាពសាច់ប្រាក់ទាក់ទង និងតម្លៃរូបិយវត្ថុសកម្មជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្តជាក់ស្តែងធនាគារត្រូវបានចូលរួមយ៉ាងសកម្មក្នុងដំណើរការនានាដែលជួយជម្រុញឱ្យមានទំនាក់ទំនងនៃប្រតិបត្តិការដើម្បីអភិវឌ្ឍសេដ្ឋកិច្ចឱ្យមានលក្ខណៈល្អប្រសើរ[27]។

---

[26] សារណាវៀមច្បងជំនាន់១៨ ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន អេឡិច.& ម៉ិចត្រេឌីង ឯ.ក ទំព័រទី ៦-៧

[27] សារណាវៀមច្បងជំនាន់ទី១៧ ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទំព័រទី៥

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# ផលប៉ះពាល់ដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

## ៣.១ ស្ថានភាពទូទៅនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

### ៣.១.១ ប្រវត្តិធនាគារជាតិ នៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានប្រវត្តិយូរអង្វែងដែលអាចបែងចែកជាបួនដំណាក់កាលដូចខាងក្រោម ៖

**ឯករាជ្យភាព និងការបង្កើតឡើងវិញ (១៩៥៤-១៩៦៤)** ៖ ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៥៤ បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីអានិគមនិយមបារាំង និងបន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ។ មុនទទួលបានឯករាជ្យវិទ្យាស្ថានបោះប្រាក់ដែលទីតាំងនៅប្រទេសកម្ពុជាបានបោះពុម្ពរូបិយវត្ថុរួមគ្នាសម្រាប់បីប្រទេសនៅឥណ្ឌូចិន គឺប្រទេសកម្ពុជា ប្រទេសឡាវ និងវៀតណាម។



រូបភាព ៖ ធនាគារជាតិនៃកម្ពុជាឆ្នាំ១៩៥៤

បន្ទាប់ពីទទួលបានឯករាជ្យធនាគារជាតិនៃកម្ពុជាបានបោះផ្សាយរូបិយវត្ថុជាតិ (ប្រាក់រៀល) ដើម្បីបំពេញអធិបតេយ្យភាពក្នុងការរក្សាស្ថិរភាពរូបិយវត្ថុ និងជួយកសាងអត្តសញ្ញាណជាតិ។ ក្នុងពេលនោះដែរប្រព័ន្ធធនាគារក្នុងស្រុកត្រូវបានកសាងឡើងវិញដែលមានទាំងធនាគាររដ្ឋ និងឯកជនធ្វើប្រតិបត្តិការរួមគ្នា។ ក្នុងសម័យសង្គមរាស្ត្រនិយមនាទសវត្សឆ្នាំ១៩៦០ ក្រោមការដឹកនាំរបស់ព្រះបាទនរោត្តមសីហនុព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍន៍រីកចម្រើនទូទាំងផ្ទៃប្រទេស។ នៅឆ្នាំ១៩៦៤ ប្រព័ន្ធធនាគារត្រូវបានធ្វើកំណែទម្រង់ដើម្បីឱ្យត្រូវតាមតម្រូវការសេដ្ឋកិច្ច និងការអភិវឌ្ឍនាសម័យនោះដោយបានប្រែក្លាយធនាគារជាតិនៃកម្ពុជាពីទម្រង់ស្ថាប័នពាក់កណ្តាលស្វ័យតទៅជាធនាគាររដ្ឋក្រោមទម្រង់ជាស្ថាប័នសាធារណៈដែលមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម ។ ទន្ទឹមនិងនេះដែរធនាគារសាធារណៈ និងឯកជនជាច្រើនត្រូវបានបិទហើយរាជរដ្ឋាភិបាលបានកសាងធនាគារដែលគ្រប់គ្រងដោយរដ្ឋមួយចំនួនដូចជាធនាគារឥណទានសម្រាប់ការអភិវឌ្ឍន៍ និងធនាគារកសិកម្មជនបទ។




រូបភាព ៖ រូបិយវត្ថុជាតិបន្ទាប់ពីទទួលបានឯករាជ្យ

**របបខ្មែរក្រហម (១៩៧៥-១៩៧៩)** ៖ នាថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) កាន់អំណាចធនាគារជាតិនៃកម្ពុជាត្រូវបានបិទទ្វារអគារស្នាក់ការត្រូវបានកម្ទេច រូបិយវត្ថុជាតិត្រូវបានឈប់ប្រើប្រាស់ហើយប្រព័ន្ធធនាគារត្រូវបានលុបបំបាត់ចោលទាំងស្រុង។ នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមត្រូវបានគេផ្តួលរំលំហើយធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្នុងនាមជាធនាគារកណ្តាលរបស់ប្រទេស និងត្រូវបានប្តូរឈ្មោះជា "ធនាគារជាតិនៃប្រជាជន កម្ពុជា" ដោយក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ ទោះជាយ៉ាងនេះក្តីការកសាងធនាគារជាតិនៃកម្ពុជា និងប្រទេសជាតិបន្ទាប់ពីសង្គ្រាមទើបបញ្ចប់ភ្លាមនេះ គឺមានការលំបាកយ៉ាងខ្លាំង។ ជាមួយនិងការខិតខំប្រឹងប្រែងជម្នះគ្រប់ឧបសគ្គដើម្បីកសាងប្រព័ន្ធធនាគារជាថ្មីឡើងវិញដោយផ្តើមចេញពីចំណុចសូន្យ (ឯកឧត្តម ជា ចាន់តូ ទេសរដ្ឋមន្ត្រីនិងជាអភិបាលធនាគារជាតិនៃកម្ពុជា និងជាអ្នកផ្តួចផ្តើមម្នាក់ក្នុងចំណោមអ្នកផ្តួចផ្តើមកសាងធនាគារជាតិនៃកម្ពុជាដទៃទៀត) ព្រមទាំងបុគ្គលិកមួយចំនួនតូចដែលរស់រានមានជីវិតពីរបបខ្មែរក្រហមបានប្តេជ្ញាចិត្តយ៉ាងមុះមុតក្នុងការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ។



រូបភាព ៖ ធនាគារជាតិនៃកម្ពុជាត្រូវដួលរំលំឆ្នាំ១៩៧៥

របបខ្មែរក្រហមបានបន្សល់ទុកនូវបញ្ហាប្រឈមជាច្រើន។ ដោយសារបញ្ញវន្តជាច្រើនរូបត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម និងខ្លះទៀតបានភៀសខ្លួនចេញពីប្រទេស បន្ទាប់ពីសង្គ្រាមចំនួនអ្នកចេះដឹង អ្នកជំនាញ និងអ្នកមានបទពិសោធន៍មានចំនួនតិចតួច។ អ្នកនៅរស់រានមានជីវិតមានសមត្ថភាពមួយចំនួនដែលនៅសេសសល់ក្នុងប្រទេសមានការភ័យខ្លាចក្នុងការធ្វើការដោយសារពួកគេមានគិតថារបបខ្មែរក្រហមអាចនិងវិលត្រឡប់មកវិញ។ លើសពីនេះទៀត គឺមានកង្វះយ៉ាងធ្ងន់ធ្ងរនៃធនធានហិរញ្ញវត្ថុក្នុងពេលដែលសេដ្ឋកិច្ចនៅទន់ខ្សោយនៅឡើយ ហើយការផ្គត់ផ្គង់សាច់ប្រាក់ស្ទើរតែមិនមានសោះដោយសារតែគោលនយោបាយរបស់ខ្មែរក្រហម សកម្មភាពសេដ្ឋកិច្ចនៅតែត្រូវបានធ្វើឡើងជាលក្ខណៈដោះដូរទំនិញនិងទំនិញ ចំណែកប្រាក់ខែមន្ត្រីរាជការស៊ីវិលត្រូវបានទូទាត់ដោយប្រើអង្ករ ត្រី ប្រេងជាដើម។ រហូតដល់ថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាបានបោះផ្សាយប្រាក់រៀលឡើងវិញដើម្បីសម្រួលដល់ការដោះដូរទំនិញ និងការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល។ បើទោះបីជាជួបប្រទះបញ្ហាប្រឈមទាំងនេះជារៀងរាល់ថ្ងៃខែឆ្នាំក៏ដោយក៏មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជានៅតែបន្តពុះពារឆ្ពោះទៅមុខជានិច្ចក្នុងការកសាងធនាគារជាតិឡើងវិញបន្តិចម្តងៗ។

**ការកសាងធនាគារជាតិនៃកម្ពុជាឡើងវិញ (១៩៧៩-១៩៩៣)** ៖ ក្នុងអំឡុងទសវត្សឆ្នាំ១៩៨០ ធនាគារនៃប្រជាជនកម្ពុជាមានតួនាទីចម្បងៗបី គឺជាអាជ្ញាធររូបិយវត្ថុជារតនាគារជាតិ និងជាអ្នកផ្តល់សេវាកម្មធនាគារដែលរួមមានសេវាឥណទាន សេវាទទួលប្រាក់បញ្ញើ និងសេវាទូទាត់ចាប់តាំងពីអគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកម្ទេចដោយខ្មែរក្រហមស្នាក់ការកណ្តាលបណ្តោះអាសន្នរបស់ធនាគារត្រូវបានបើកនៅជាន់លើនៃធនាគារខ្មែរពាណិជ្ជ។ ធនាគារប្រជាជននៃកម្ពុជាបានបង្កើតរចនាសម្ព័ន្ធដឹកនាំក៏ដូចជាសកម្មភាពប្រតិបត្តិការជាច្រើនទៀត និងបានពង្រីកបណ្តាញសាខារបស់ខ្លួនដល់២៤ខេត្ត-ក្រុងទូទាំងប្រទេស។ ចាប់តាំងពីឆ្នាំ១៩៨៩ មកប្រព័ន្ធធនាគារបានធ្វើកំណែទម្រង់បន្តិចម្តងៗតាមរយៈការផ្លាស់ប្តូរធនាគារខេត្ត-ក្រុងចំនួន២០ទៅជាធនាគារឯកទេសខេត្ត-ក្រុងហើយធ្វើប្រតិបត្តិការជាមួយនឹងស្វ័យភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៅក្នុងដែនដីរបស់ពួកគេ។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុធនាគារនៃប្រជាជនកម្ពុជាបានត្រួតពិនិត្យលើដំណើរការរបស់ធនាគារពាណិជ្ជទាំងនោះអគារស្នាក់ការធនាគារជាតិនៃកម្ពុជាត្រូវបានកសាងឡើងវិញនៅឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩១ ធនាគារពាណិជ្ជដំបូងគេ (ធនាគារពាណិជ្ជកម្ពុជា"CCB") ត្រូវបានបង្កើតឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋដើម្បីទាក់ទាញវិនិយោគិន និងបម្រើឱ្យសកម្មភាពអាជ្ញាធរអ៊ុនតាក់ប្រចាំនៅកម្ពុជា។ សន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១ បានផ្លាស់ប្តូររបបសេដ្ឋកិច្ចកម្ពុជាពីសេដ្ឋកិច្ចផែនការមកជាសេដ្ឋកិច្ចទីផ្សារសេរី។ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការប្តូរឈ្មោះនិងកាតព្វកិច្ចរបស់ធនាគារជាតិនៃកម្ពុជាពី "ធនាគារនៃប្រជាជនកម្ពុជា "មកជា" ធនាគារជាតិនៃកម្ពុជា" វិញដែលត្រូវបានប្រកាសឱ្យប្រើដោយក្រុមប្រឹក្សារដ្ឋនាថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩២។ ធនាគារជាតិនៃកម្ពុជាបានចងក្រងនិងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅឆ្នាំ២០០១-២០១០។ ឯកសារនេះមានមុខងារជាមូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុដើម្បីបង្កើនទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធធនាគារ និងវិធីសាស្ត្រដែលកម្ពុជាអាចធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល។ ក្នុងនាមជាធនាគារកណ្តាលរបស់ជាតិ ធនាគារជាតិនៃកម្ពុជាធ្វើការកែលម្អអគារស្នាក់ការនៅឆ្នាំ២០០៣ដើម្បីលើកមុខមាត់ និងកិត្យានុភាពរបស់ខ្លួន។ ប្រព័ន្ធធនាគារនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ នៅ

ពេលដែលច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងច្បាប់ និងបទប្បញ្ញត្តិនានាក៏ដូចជាគន្លឹះនៃការធ្វើកំណែទម្រង់វិស័យធនាគារសំខាន់ផ្សេងទៀតត្រូវបានអនុវត្ត ។



រូបភាព ៖ ធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន

**ទំនើបភាវូនីយកម្មប្រព័ន្ធធនាគារ (១៩៩៣-បច្ចុប្បន្ន)** ៖ បច្ចុប្បន្នប្រព័ន្ធធនាគារនៅកម្ពុជារួមមានធនាគារពាណិជ្ជចំនួន៣៦ ធនាគារឯកទេសចំនួន១១ តំណាងធនាគារបរទេសចំនួន៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៣(ក្នុងនោះរួមបញ្ចូលទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៧) ប្រតិបត្តិករឥណទានជនបទ ចំនួន៣៨ ក្រុមហ៊ុនជួលចំនួន៦ ការិយាល័យឥណទានចំនួន១, ដំណើរការតតីយភាគី ចំនួន៦និងអាជីវករប្តូរប្រាក់ចំនួន១.៧៧០។ គ្រឹះស្ថានធនាគារហិរញ្ញវត្ថុបានកំពុងបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនតាមរយៈការបើកសាខា និងការិយាល័យតំណាងជាច្រើនកន្លែងក្នុងរាជធានី-ខេត្ត និងតម្លើងម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ(អេធីអឹម)បន្ថែមលើការផ្តល់សេវាទូទាត់អេឡិចត្រូនិក។ ប្រព័ន្ធធនាគារនៅកម្ពុជាមានដំណើរយ៉ាងវែងឆ្ងាយពោល គឺចាប់តាំងពីការកសាងមូលដ្ឋានគ្រឹះប្រព័ន្ធធនាគារបន្ទាប់ពីបានទទួលឯករាជ្យមកការបំផ្លិចបំផ្លាញនៃប្រព័ន្ធរូបិយវត្ថុក្នុងរបបខ្មែរក្រហម បន្ទាប់មកការទូទាត់ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលដោយអង្ករ និងត្រីរហូតដល់ការកសាងវិស័យធនាគារ និងហិរញ្ញវត្ថុដែលប្រកបដោយការគ្រប់គ្រងយ៉ាងល្អ និងចាក់ស្រេះចាប់តាំងពីបាតដៃទទេ។




រូបភាព ៖ម៉ាស៊ីនដាក់-ដកដោយស្វ័យប្រវត្តិ (អេធីអឹម)

**៣.១.២ បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា**

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថិរភាពថ្លៃដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្នអតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្តីក្នុងស្ថានភាពសេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ។ បច្ចុប្បន្នឧបករណ៍គោលនយោបាយរូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និងការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់។ ជាមួយគ្នានេះធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍន៍ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុតាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបានការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សាររូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល ។

**៣.១.៣ មុខងារ និងភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា**

ធនាគារជាតិនៃកម្ពុជាមានមុខងារ និងភារកិច្ចដូចតទៅ៖

- កំណត់គោលដៅគោលនយោបាយរូបិយវត្ថុដោយពិគ្រោះជាមួយរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា
- ត្រិះរិះរកអនុវត្តត្រួតពិនិត្យគោលនយោបាយរូបិយវត្ថុ និងគ្រប់គ្រងការប្តូរប្រាក់ឱ្យសម្រេចទៅតាមគោលដៅដែលបានកំណត់
- ធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រក្រតីរួចចេញផ្សាយលទ្ធផលហើយលើកជាសំណើ និងវិធានការជូនរាជរដ្ឋាភិបាល
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណអាជីវកម្មចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឯទៀតដែលពាក់ព័ន្ធដូចជាស្នងការគណនីគ្រឹះស្ថានជម្រះបញ្ជីជាដើមព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនោះ
- ត្រួតពិនិត្យប្រព័ន្ធទូទាត់ក្នុងព្រះរាជាណាចក្រកម្ពុជា និងកែលម្អប្រសិទ្ធភាពនៃការទូទាត់អន្តរធនាគារ
- ទទួលភារៈផ្តាច់មុខជាអ្នកបោះផ្សាយរូបិយវត្ថុជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ទទួលខុសត្រូវ និងអនុវត្តក្នុងនាមព្រះរាជាណាចក្រនៃកម្ពុជានូវកិច្ចការទាំងឡាយដែលជាលទ្ធផលនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិសាធារណៈក្នុងកិច្ចការធនាគារឥណទានរូបិយវត្ថុ។
- ដំឡើងតារាងជញ្ជាំងទូទាត់
- ចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យជាមួយប្រទេសក្រៅ
- ចូលរួមក្នុងការបង្កើតការត្រួតពិនិត្យទីផ្សាររូបិយវត្ថុ និងទីផ្សាហិរញ្ញវត្ថុ
- ផ្តល់ ឬដកហូតអាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានដែលចូលរួមក្នុងអាជីវកម្មទីផ្សារប្តូរប្រាក់ មូលបត្រ ត្បូងថ្ម និងលោហធាតុមានតម្លៃព្រមទាំងចេញបទបញ្ជា និងត្រួតពិនិត្យគ្រឹះស្ថានទាំងនេះ

- កំណត់អត្រាការប្រាក់។

### ៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា




រូបភាព៖ រចនាសម្ព័ន្ធ ធនាគារជាតិនៃកម្ពុជា

ក្រុមប្រឹក្សាភិបាលជាគណៈគ្រប់គ្រងដែលមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចលើផែនការ និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា។ ធនាគារជាតិនៃកម្ពុជាមានសមាសភាពចំនួន៧រូប គឺទេសាភិបាល ទេសាភិបាលរង តំណាងប្រមុខរដ្ឋាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងមជ្ឈដ្ឋានឧត្តមសិក្សា តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច និងតំណាងមន្ត្រី-បុគ្គលិកធនាគារធនាគារជាតិនៃកម្ពុជា។ ទេសាភិបាល ជាប្រធានក្រុមប្រឹក្សាភិបាលមានតួនាទីជានាយកប្រតិបត្តិនៃធនាគារជាតិនៃកម្ពុជាជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលខុសត្រូវចំពោះកិច្ចការអនុវត្តគោលនយោបាយនិងប្រតិបត្តិការប្រចាំថ្ងៃ។ ទេសាភិបាលត្រូវបានតែងតាំងដាក់ជំនួស និងបញ្ឈប់ពីតំណែងដោយព្រះរាជក្រឹត្យដែលយោងតាមសំណើរបស់រាជរដ្ឋាភិបាល។ ក្នុងកម្រិតបច្ចេកទេសធនាគារជាតិនៃកម្ពុជាមានប្រាំអគ្គនាយកដ្ឋាន គឺអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យអគ្គបេឡា និងអគ្គាធិការដ្ឋានដែលក្នុងនោះរួមមាន២១នាយកដ្ឋានដឹកនាំដោយប្រធាននាយកដ្ឋាន។ នាយកដ្ឋាន និងអគ្គនាយកដ្ឋានមានតួនាទីទទួលខុសត្រូវចំពោះការអនុវត្តមុខងារប្រចាំថ្ងៃនៃប្រតិបត្តិការធនាគារកណ្តាល និងគោលនយោបាយរបស់ធនាគារជាតិនៃកម្ពុជា ។

## ៣.២ ផលប៉ះពាល់នៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា

ការបាត់បង់ទំនុកចិត្តលើប្រាក់រៀល បានធ្វើឱ្យដុល្លារអាមេរិកក្លាយទៅជារូបិយបណ្ណដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយបំផុតនៅក្នុងប្រទេសកម្ពុជាពោល គឺត្រូវបានគេប្រើច្រើនជាងប្រាក់រៀលដែលជារូបិយវត្ថុជាតិទៅទៀត។ តើការប្រើប្រាក់ដុល្លារយ៉ាងទូលំទូលាយបែបនេះអាចបង្កនូវផលវិបាកអ្វីខ្លះ? នៅកម្ពុជាដុល្លារអាមេរិកត្រូវបានគេប្រើប្រាស់ជាមធ្យោបាយសម្រាប់កំណត់តម្លៃ សម្រាប់ទូទាត់ និងសម្រាប់សន្សំ ពោលគឺតួនាទីសំខាន់ៗទាំង៣នៃរូបិយបណ្ណ។ តម្លៃទំនិញភាគច្រើនត្រូវគិតជាដុល្លារការទិញដូរភាគច្រើនត្រូវទូទាត់ដោយប្រើប្រាស់ប្រាក់ដុល្លារហើយការដាក់ប្រាក់សន្សំនៅធនាគារភាគច្រើនត្រូវដាក់ជាដុល្លារ។



រូបភាព៖ ប្រាក់ដុល្លារអាមេរិក

ដុល្លារនៅក្នុងយោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ ( **International Monetary Fund** ) នៅកម្ពុជាដុល្លារត្រូវបានប្រើប្រាស់សាច់ប្រាក់សរុបដែលចរាចរនៅលើទីផ្សារហើយខុសពីប្រទេសជិតខាងដូចជាប្រទេសឡាវជាដើមដែលការប្រើប្រាក់ដុល្លារមានការថយចុះធៀប និងប្រាក់ជាតិនិន្នាការនៃការប្រើប្រាក់ដុល្លារនៅកម្ពុជាវិញមិនមានការថយចុះទាល់តែសោះទោះបីជាកម្ពុជាមានស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ហើយមានអត្រាអតិផរណា

មិនខ្ពស់ហួសហេតុក៏ដោយ។ ការអនុញ្ញាតឱ្យប្រើប្រាស់ប្រាក់ដុល្លារយ៉ាងទូលំទូលាយបែបនេះអាចផ្តល់នូវគុណប្រយោជន៍មួយចំនួន ក៏ប៉ុន្តែក៏អាចបង្កនូវផលវិបាកអវិជ្ជមានច្រើនផងដែរដល់សេដ្ឋកិច្ចខ្មែរ។ ការគ្របដណ្តប់នៃក្រដាសប្រាក់ប្រទេសមានផលប៉ះពាល់ទៅលើសេដ្ឋកិច្ចនិងសង្គមជាតិ។ ជាបឋមការគ្របដណ្តប់នេះបានចោទជាបញ្ហាទៅលើសិទ្ធិនៃការបោះពុម្ពក្រដាសប្រាក់។ សិទ្ធិនេះពាក់ព័ន្ធនិងភាពខុសគ្នារវាងតម្លៃពិតនៃរូបិយវត្ថុ (តម្លៃពិតនៃការផលិត និងការចែកចាយកាក់ រឺក្រដាសប្រាក់ធនាគារ) និងតម្លៃទិញរូបិយវត្ថុនៅលើទីផ្សារ (តម្លៃសន្មត)។ បាត់បង់សិទ្ធិលើការបោះពុម្ពក្រដាសប្រាក់នេះមានន័យថារដ្ឋបាត់បង់ប្រាក់ចំណូលដែលបានមកពីការបោះពុម្ពរូបិយវត្ថុ។ បន្ទាប់មកការប្រើប្រាស់ប្រាក់ដុល្លារធ្វើឱ្យមានការធ្លាក់ចុះនៃទុនបម្រុងផ្លូវការ និងកំណត់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុដែលត្រូវបានដាក់ឱ្យអនុវត្តន៍ដោយធនាគារជាតិនៃកម្ពុជាព្រមទាំងឥទ្ធិពលលើអត្រាប្តូរប្រាក់។ ធនាគារជាតិនៃកម្ពុជាកាន់តែងាយទទួលរងផលប៉ះពាល់ពីវិបត្តិខាងក្រៅប្រទេសពាក់ព័ន្ធ និងបញ្ហាសង្គមដុល្លារូបនីយកម្មដើរតួនាទីអវិជ្ជមានមួយរវាង អ្នកមាននិងអ្នកក្រីក្រ ការទិញជាមួយនិងបរិមាណដ៏ច្រើនអាចប្រព្រឹត្តធ្វើទៅបានជាមួយតែរូបិយបណ្ណដុល្លារប៉ុណ្ណោះ។ ប៉ុន្តែមានតែប្រជាជនកម្ពុជាដែលមានធនធានហិរញ្ញវត្ថុជាដុល្លារ ឬជនបរទេសប៉ុណ្ណោះដែលអាចទិញទំនិញទាំងនោះបានមានតែពួកគេប៉ុណ្ណោះដែលអាចមានគណនីនៅក្នុងធនាគារគិតជាដុល្លារ។ ក្រៅពីនេះប្រជាជនកម្ពុជាដែលមានប្រាក់ខែជាប្រាក់រៀលខាតបង់យ៉ាងច្រើននៅពេលពួកគេដូរប្រាក់ជាដុល្លារ ហើយពួកគេកាន់តែពឹងផ្អែកលើទីផ្សារប្តូរប្រាក់ជាងគេ។ ហេតុដូច្នេះហើយទើបបានជាប្រជាជនក្រីក្រ គឺជាអ្នកទាមទារឱ្យមានបដិដុល្លាររូបនីយកម្មនៅប្រទេសកម្ពុជាខ្លាំងជាងគេបំផុត។

### ៣.២.១ វត្តមានប្រាក់ដុល្លារូបនីកម្មនៅកម្ពុជា

ក្នុងអំឡុងរបបខ្មែរក្រហមរូបិយវត្ថុត្រូវបានលុបបំបាត់ចោលពោលគឺគ្មានទីផ្សារ គ្មានពាណិជ្ជកម្ម និងគ្មានសេរីភាពគ្រប់យ៉ាង។ ក្រោយរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាបានចាប់ផ្តើមទទួលបានសន្តិភាពមកវិញ។ បន្ទាប់ពីធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងសាជាថ្មីនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ធនាគារជាតិនៃកម្ពុជាក៏បានបោះផ្សាយប្រាក់រៀលជាតិឡើងវិញផងដែរនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ប៉ុន្តែភាពជឿជាក់និងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀលនៅមានកម្រិត និងផុយស្រួយនៅឡើយក្រោយពីសង្គ្រាមទើបត្រូវបានបញ្ចប់ភ្លាមៗ។

នៅដើមទស្សវត្សរ៍ឆ្នាំ១៩៩០ អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (**UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA**) បានមកកាន់ប្រទេសកម្ពុជាដើម្បីរៀបចំការបោះឆ្នោតជាតិជាលើកទីមួយ។ ក្នុងអំឡុងពេលនោះប្រាក់ដុល្លារយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានយកមកប្រើប្រាស់សម្រាប់ការទូទាត់ក្នុងសេដ្ឋកិច្ចកម្ពុជា។ ប្រជាជនកម្ពុជាបានចាប់ផ្តើមស្គាល់ពីតម្លៃរបស់ប្រាក់ដុល្លារ ហើយបានប្រើប្រាស់កាន់តែច្រើនឡើងៗក្នុងប្រតិបត្តិការពាណិជ្ជកម្មនិងជំនួញ។ ដោយការរក្សាបាននូវស្ថិរភាព និងការបើកចំហនៃសេដ្ឋកិច្ចសកម្មភាពពាណិជ្ជកម្មទេសចរណ៍ហើយការវិនិយោគបរទេសបានកើនឡើងជាបន្តបន្ទាប់ និងបានជំរុញដល់ការរីកចម្រើនសេដ្ឋកិច្ច។ ជាលទ្ធផលប្រាក់ដុល្លារទទួលបានការពេញនិយមកាន់តែច្រើន និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ស្ទើរគ្រប់សកម្មភាពជំនួញ ជាពិសេសប្រតិបត្តិការដែលមានទំហំទឹកប្រាក់ធំនៅតាមទីប្រជុំជន។ ទោះជាយ៉ាងណាក៏ដោយផ្អែកតាមការស្ទាបស្ទង់មតិមួយចំនួនបានបង្ហាញថាប្រាក់រៀលជាតិត្រូវបានប្រើប្រាស់យ៉ាងសកម្មនៅតាមទីជនបទ និងក្នុងប្រតិបត្តិ

ការដែលមានទំហំទឹកប្រាក់តូចសម្រាប់ជាមធ្យោបាយទូទាត់សន្សំ និងផ្តល់ឥណទាន។ គួរកត់សម្គាល់ផងដែរថាតម្រូវការប្រាក់រៀលមានការកើនឡើងជាបន្តបន្ទាប់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ និងកំពុងបន្តកើនឡើងបន្ថែមទៀត។

**៣.២.២ ប្រភេទនៃដុល្លាររូបនីយកម្ម**

ដុល្លាររូបនីយកម្មត្រូវបានបែងចែកចេញជាបីប្រភេទធំៗគឺដុល្លាររូបនីយកម្មផ្លូវការ ដុល្លាររូបនីយកម្មពាក់កណ្តាលផ្លូវការ និងដុល្លាររូបនីយកម្មមិនផ្លូវការ ។

**ដុល្លាររូបនីយកម្មផ្លូវការ** (Official Dollarization): គឺជាស្ថានភាពមួយដែលរូបិយបណ្ណបរទេសត្រូវបានអនុម័តជាផ្លូវការដើម្បីប្រើប្រាស់ដោយស្របច្បាប់ជំនួសរូបិយវត្ថុក្នុងស្រុក។ ការសម្រេចចិត្តនេះត្រូវបានគេសង្កេតឃើញនៅក្នុងប្រទេសមួយចំនួនដែលធ្លាប់បានជួបវិបត្តិសេដ្ឋកិច្ចធ្ងន់ធ្ងរ និងការបាត់បង់ជំនឿចិត្តទាំងស្រុងលើរូបិយវត្ថុជាតិខ្លួន មានន័យរូបិយបណ្ណបរទេសបានក្លាយជាការទូទាត់ដ៏ពេញនិយមនៅក្នុងប្រទេសខណៈរូបិយបណ្ណក្នុងស្រុកក៏អាចប្រើប្រាស់បានដែរឧទាហរណ៍ប្រាក់ដុល្លារអាមេរិក។

**ដុល្លាររូបនីយកម្មពាក់កណ្តាលផ្លូវការ** (Semi-official Dollarization): គឺសំដៅដល់ស្ថានភាពដែលរូបិយបណ្ណបរទេស និងរូបិយវត្ថុជាតិត្រូវបានប្រើប្រាស់ដោយសេរីនៅក្នុងទីផ្សារដោយសារតែប្រជាពលរដ្ឋភាគច្រើនយល់ថារដ្ឋាភិបាលទទួលយកការប្រើប្រាស់រូបិយបណ្ណបរទេស បើទោះបីជាមិនមានការប្រកាសជាផ្លូវការពីការទទួលស្គាល់ក៏ដោយ។

**ដុល្លាររូបនីយកម្មមិនផ្លូវការ** (Unofficial Dollarization): គឺសំដៅដល់ពេលដែលប្រជាពលរដ្ឋនៃប្រទេសមួយរក្សាទុកទ្រព្យសម្បត្តិរបស់ពួកគេជាពិសេសទ្រព្យសកម្មក្នុងទម្រង់ជារូបិយបណ្ណបរទេសតាមរយៈការទិញបណ្ណបំណុល ឬភាគហ៊ុនដែលសេដ្ឋវិទូហៅថាការជំនួសទ្រព្យសកម្ម និងមួយទៀតដែលចាប់ផ្តើមបញ្ញើ និងសន្សំជារូបិយបណ្ណបរទេសដែលត្រូវបានគេហៅថាការជំនួសរូបិយវត្ថុជាតិ។ បើទោះបីជារូបិយបណ្ណនោះមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការទូទាត់ដោយស្របច្បាប់ក៏ដោយនៅចុងក្រោយដុល្លាររូបនីយកម្មមិនផ្លូវការនេះ និងមានលក្ខណៈដែលថាប្រជាពលរដ្ឋទាំងអស់ចាប់ផ្តើមគិតតម្លៃទំនិញ និងសេវាជារូបិយបណ្ណបរទេសហើយធ្វើការទូទាត់ជារូបិយវត្ថុក្នុងស្រុកដោយគិតតាមអត្រាប្តូរប្រាក់ជាក់លាក់មួយ។ ដុល្លាររូបនីយកម្មក្រៅផ្លូវការមានន័យថាជាស្ថានភាពដែលប្រជាជនចូលចិត្តប្រើប្រាស់រូបិយបណ្ណបរទេសសម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុមួយចំនួនទោះបីជាវាមិនមែនជាការទូទាត់មានលក្ខណៈផ្លូវការក៏ដោយ ឧទាហរណ៍តំបន់នៅជាប់ព្រំដែនរវាងប្រទេស និងប្រទេសតែងមានការទូទាត់លើប្រតិបត្តិការមួយចំនួននូវរូបិយបណ្ណក្នុងស្រុក និងរូបិយបណ្ណបរទេសលាយឡំគ្នា។

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសដុល្លាររូបនីយកម្មមិនផ្លូវការដោយសារតែប្រជាពលរដ្ឋប្រើប្រាស់ប្រាក់បរទេសលាយលំជាមួយប្រាក់រៀលមិនថាជាប្រាក់ដុល្លារអាមេរិក ប្រាក់បាតថៃ និងប្រាក់ដុងវៀតណាមជាដើមបើទោះបីជាមិនមានការទទួលស្គាល់ជាផ្លូវការក៏ដោយ។ លក្ខណៈបែបនេះវានិង

ធ្វើឱ្យប្រសិទ្ធិភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារអាច និងមិនមានប្រសិទ្ធិភាពទៅលើឧបករណ៍គោលនយោបាយមួយចំនួនដោយសារតែធនាគារជាតិមិនមានអំណាចនៅក្នុងការគ្រប់គ្រងរូបិយបណ្ណបរទេស។ ដោយឡែកធនាគារជាតិនៃកម្ពុជានាពេលថ្មីៗនេះបានដាក់ចេញនូវវិធានការប្រមូលយកប្រាក់ដុល្លារអាមេរិកប្រភេទ ១$ ២$ និង៥$ដែលនៅសេសសល់ក្នុងឃ្លាំងយ៉ាងច្រើនរបស់ធនាគារពាណិជ្ជដើម្បីបញ្ជូនត្រលប់ទៅប្រទេសដើមវិញ ដែលនេះជាការធ្វើបដិដុល្លារូបនីយកម្មមួយក្នុងគោលដៅលើកតម្កើនការប្រើប្រាស់ប្រាក់រៀលក្នុងប្រតិបត្តិការតូចៗឡើងវិញ។

**៣.២.៣ គុណសម្បត្តិ និងគុណវិបត្តិនៃដុល្លារូបនីយកម្ម**

ការចរាចររូបិយបណ្ណបរទេសនៅកម្ពុជាត្រូវបានគេសង្កេតឃើញមានស្ទើរតែទូទាំងប្រទេសជាពិសេសប្រាក់ដុល្លារអាមេរិក។ ទន្ទឹមនិងការចរាចរណ៍រូបិយបណ្ណបរទេសនេះនាំឱ្យមានគុណសម្បត្តិ និងវិបត្តិអ្វីខ្លះដល់សេដ្ឋកិច្ចជាតិ?







គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ដុល្លារបើតាមរបាយការណ៍ស្តីពីការពង្រឹងការប្រើប្រាស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញនូវគុណសម្បត្តិដូចខាងក្រោម ៖

➢ **គុណសម្បត្តិ**

- ប្រាក់ដុល្លារអាមេរិកមានតម្លៃល្អគេបានប្រើប្រាស់វាជាទូទៅក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិភាគច្រើនព្រោះជាកញ្ចប់លុយអន្តរជាតិ។
- ពាក់ព័ន្ធនិងអត្រាប្តូរប្រាក់មានការប្រែប្រួលរហូតទើបធ្វើឱ្យការប្រើប្រាស់លុយរៀលខាត និងចំណេញមិនទៀង។
- ប្រើដើមទុនជាដុល្លារនៅពេលគាត់ចង់បង្វិលប្រាក់ចំណូលទៅប្រទេសគាត់វិញមានភាពពេលឆ្លងកាត់ប្រព័ន្ធធនាគារដែលជាហេតុធ្វើឱ្យមានភាពទាក់ទាញដល់វិនិយោគិនមកពីក្រៅប្រទេស ។
- មានភាពងាយស្រួលដល់វិនិយោគិនបរទេសដែលត្រូវនាំចូលនូវមូលធនដូចជា សម្ភារៈគ្រឿងម៉ាស៊ីនផ្សេងៗមកវិនិយោគសាងសង់នៅប្រទេសយើង គឺអត់មានការលំបាកទេពីព្រោះគាត់ទិញគ្រឿងសម្ភារៈទាំងអស់នោះមកជាប្រាក់ដុល្លារហើយទូទាត់ទៅវិញមានភាពងាយស្រួល និងមិនធ្វើឱ្យប៉ះពាល់ដល់អត្រាប្តូរប្រាក់ថែមទៀត ។
- ដុល្លារូបនីយកម្មអាចជួយទប់ស្កាត់លំហូរចេញនៃដើមទុន និងជំរុញការលើកទឹកចិត្តដល់សាធារណជនក្នុងការសន្សំប្រាក់នៅក្នុងប្រទេសដោយសារតែពួកគេមិនប្រឈម និងហានិភ័យអត្រាប្តូរប្រាក់។

- ដុល្លារូបនីយកម្មអាចជាកត្តាជួយការពារប្រទេសកម្ពុជាពីការរីករាលដាលនៃវិបត្តិរូបិយវត្ថុនៅអាស៊ីនាឆ្នាំ១៩៩៧ និងជួយរក្សាជំនឿទុកចិត្តអ្នកវិនិយោគក្នុងប្រតិបត្តិការរបស់របស់ពួកគេប្រនៅទេសកម្ពុជាខណៈដែលប្រទេសអាស៊ីជាច្រើនបានទទួលរងគ្រោះពីវិបត្តិនេះ។ ទន្ទឹមនិងការអនុវត្តរបបប្តូរប្រាក់អណ្តែត ប្រទេសកម្ពុជាស្ថិតក្នុងបរិស្ថានដែលមានខឿនសេដ្ឋកិច្ចនៅតូច ហើយវិស័យធនាគារក៏មានទំហំតូចនៅឡើយ រីឯទីផ្សារហ៊ុនក៏ពុំទាន់មាន។ ដូចនេះគុណសម្បត្តិចំណុចនេះអាចនិងពុំទទួលបានឡើយ ប្រសិនបើសេដ្ឋកិច្ចកម្ពុជាមិនស្ថិតក្នុងបរិស្ថានដូចបានកត់សម្គាល់នោះ។
- ការប្រើប្រាស់ដុល្លារបានជួយដល់ដំណើរការសមាហរណកម្មវិស័យពាណិជ្ជកម្មអន្តរជាតិដោយសារប្រាក់ដុល្លារត្រូវបានប្រើប្រាស់ក្នុងការដោះដូរអន្តរជាតិទាំងក្នុងតំបន់ និងពិភពលោក។ កម្រឹតបើកចំហពាណិជ្ជកម្មអន្តរជាតិនៃសេដ្ឋកិច្ចកម្ពុជា (ការនាំចេញនិងនាំចូលសរុបធៀបនិង ផ.ស.ស) បានកើនឡើងពី៣៨%នៅឆ្នាំ១៩៩៣ ដល់ ១០៧%នៅឆ្នាំ២០១៣)
- ដុល្លារូបនីយកម្មបានកាត់បន្ថយនូវហានិភ័យប្តូរប្រាក់ និងកេងរកចំណេញពីការធ្វើឱ្យអត្រាប្តូរប្រាក់ប្រែប្រួល។ ដោយសារការប្រើប្រាស់ប្រាក់រៀលមានកម្រិតទាបអង្គាធររូបិយវត្ថុអាចគ្រប់គ្រងលើចរាចរណ៍រូបិយវត្ថុជាតិ និងអត្រាប្តូរប្រាក់ហើយអ្នកកេងចំណេញលើអត្រាប្តូរប្រាក់ក៏មិនអាចកេងចំណេញច្រើនពីការធ្វើឱ្យប្រែប្រួលលើអត្រាប្តូរប្រាក់ដែរ។ កត្តានេះរួមចំណែកធ្វើឱ្យកម្ពុជាអាចគេចផុតពីការប្រឈមនិងវិបត្តិហិរញ្ញវត្ថុអាស៊ីកាលពីឆ្នាំ១៩៩៧-១៩៩៨។
- ដុល្លារូបនីយកម្មបានជំរុញប្រជាជនឱ្យងាកពីការនិយមប្រើប្រាស់ប្រាក់ដុល្លារអាមេរិកវិញក្នុងការទូទាត់ឬមធ្យោបាយរក្សាទ្រព្យសម្បត្តិនៅដើមសតវត្សរ៍ទី៩០។
- ដុល្លារូបនីយកម្មបានចូលរួមចំណែករក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចតាមរយៈការរក្សាស្ថេរភាពថ្លៃ និងពង្រឹកការគោរពវិន័យសារពើពន្ធ (Fiscal discipline) ជាពិសេសក្នុងដំណាក់កាលដែលសេដ្ឋកិច្ចកម្ពុជាបានជួបប្រទះនិងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច។ ប្រាក់ដុល្លារត្រូវបានចាត់ទុកជារូបិយបណ្ណដែលមានស្ថេរភាពថ្លៃធៀប និងរូបិយបណ្ណនានាដូច្នេះការប្រើប្រាស់ប្រាក់ដុល្លារក៏បានបន្ថយឥទ្ធិពលអត្រាប្តូរប្រាក់លើអត្រាអតិផរណាផងដែរ។ ទន្ទឹមនេះរដ្ឋាភិបាលមិនពឹងផ្អែកលើការបោះពុម្ពរូបិយវត្ថុដើម្បីធ្វើហិរញ្ញប្បទានឱនភាពថវិការរដ្ឋដែលធ្វើឱ្យមានផលវិជ្ជមានដល់ការគ្រប់គ្រងសម្ពាធអតិផរណា និងពង្រឹងគោលនយោបាយសារពើន្ធ។
- ក្នុងពេលដែលសាធារណជនមិនមានទំនុកចិត្តលើលុយរៀលការអនុញ្ញាតឱ្យចាយលុយដុល្លារអាចបញ្ចៀសកុំឱ្យកម្ពុជាត្រូវប្រឈមមុខ និងចលនាហូរចេញមូលធនទៅក្រៅប្រទេស។
- អត្ថប្រយោជន៍នៃការធ្វើរូបិយបណ្ណដុល្លារដោយសារកង្វះទំនុកចិត្តសាធារណៈលើប្រាក់រៀល រូបិយបណ្ណដុល្លារូបនីយកម្មបានជួយក្នុងការរក្សាសមត្ថភាពទូទាត់នៅក្នុងប្រទេសកម្ពុជា។
- ការដាក់បញ្ចូលក្រដាសប្រាក់ក្នុងបរិមាណច្រើនជាប្រាក់ដុល្លារ នៅដើមទសវត្សរ៍ឆ្នាំ1990 បានអនុញ្ញាតឱ្យសាធារណជនប្តូរពីការប្រើប្រាស់មាសទៅជាក្រដាសប្រាក់សម្រាប់ប្រតិបត្តិការ និងរក្សាទុកទ្រព្យសម្បត្តិ។ រហូតមកដល់ពេលនោះការប្រើប្រាស់ទ្រព្យសកម្មដែលមិនបានបង្កើតផលដូចជាមាសជាទម្លាប់ទូទៅនៅកម្ពុជា ជាបន្តបន្ទាប់វិឌ្ឍនភាពនៃការរកប្រាក់បានជំរុញឱ្យមានការសន្សំនៅក្នុងវណ្ណៈកណ្តាល។

- ប្រាក់ដុល្លារបានរារាំងការហោះហើរដើមទុន និងជំរុញការធ្វើឱ្យស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ។ ការលុបបំបាត់ការលើកទឹកចិត្តដើម្បីដាក់ប្រាក់សន្សំនៅក្រៅប្រទេសបានលើកទឹកចិត្តដល់អន្តរការីហិរញ្ញវត្ថុក្នុងស្រុក ដែលបណ្តាលឱ្យមានការរីកចម្រើននៃប្រព័ន្ធហិរញ្ញវត្ថុ។ ត្រឹមតែរយៈពេលបីឆ្នាំចុងក្រោយនេះបរិមាណនៃសកម្មភាពធនាគារបានកើនឡើងប្រហែលទ្វេដង ហើយសមាមាត្រប្រាក់កម្ចីទៅនិងប្រាក់បញ្ញើបានកើនឡើងជាទៀងទាត់។
- រូបិយបណ្ណដុល្លារបានកាត់បន្ថយហានិភ័យនៃការធ្លាក់ថ្លៃរូបិយបណ្ណ។ តម្រូវការប្រាក់រៀលនៅមានកម្រិតទាបហើយទីផ្សារតូចខ្លាំង ដូច្នេះមានការលើកទឹកចិត្តតិចតួចសម្រាប់អ្នកប្រមើលមើលដើម្បីព្យាយាមទទួលបានពីការផ្លាស់ប្តូរតម្លៃប្រាក់រៀលក្នុងរយៈពេលខ្លី។ ប្រាក់ដុល្លារបានការពារប្រទេសកម្ពុជាពីការឆ្លងរាលដាលនៅពេលប្រឈមមុខ និងវិបត្តិអាស៊ី(1997-2000)។ វារក្សានូវទំនុកចិត្តរបស់អ្នកវិនិយោគក្នុងប្រតិបត្តិការរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា រូបិយបណ្ណដុល្លារបានលើកកម្ពស់ការយល់ដឹងដោយអ្នកបង្កើតគោលនយោបាយអំពីតម្រូវការដើម្បីជៀសវាងការផ្តល់ហិរញ្ញប្បទានពីធនាគារនៃឱនភាពសាធារណៈ។
- ការប្រើប្រាស់ប្រាក់ដុល្លារបានជួយសម្រួលដល់ដំណើរការសមាហរណកម្មពាណិជ្ជកម្មកម្ពុជាក្នុងសេដ្ឋកិច្ចអន្តរជាតិ។ ស្ថិរភាពរូបិយបណ្ណបានលើកកម្ពស់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបរិយាកាសអាជីវកម្មដែលអាចព្យាករណ៍បាន ហើយនិងកាត់បន្ថយការចំណាយលើប្រតិបត្តិការ(ជៀសវាងការបំប្លែងរូបិយបណ្ណ) វាអនុញ្ញាតឱ្យមានការរីកចម្រើនក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា។

➢ **គុណវិបត្តិ**

- ដុល្លារូបនីយកម្មធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយរូបិយវត្ថុ (monetary policy) ឱ្យមានប្រសិទ្ធភាព និងហួសពីការគ្រប់គ្រងរបស់ធនាគារជាតិ ហើយក្នុងនាមជាអ្នកផ្តល់កម្ចីចុងក្រោយ (lender of last resort) ក៏បានប្រឈម និងបញ្ហាសាច់ប្រាក់យ៉ាងខ្លាំង។
- ការប្រើប្រាស់លុយដុល្លារច្រើនធ្វើឱ្យរូបិយវត្ថុជាតិធ្លាក់តម្លៃ ហើយបាត់បង់ភាពជានិមិត្តរូបនៃអធិបតេយ្យភាព និងជាតិសាសន៍។
- ធនាគារជាតិទទួលបានចំណូលពីការបោះពុម្ពសាច់ប្រាក់នៅពេលប្រាក់នោះចរាចរណ៍ក្នុងទីផ្សារសេដ្ឋកិច្ច ដោយសារការប្រើប្រាស់លុយដុល្លារច្រើនក្នុងទីផ្សារ ធនាគារជាតិបាត់បង់ប្រាក់ចំណូលប្រចាំឆ្នាំប្រមាណចន្លោះពី 20 ទៅ 90 លានដុល្លារក្នុងមួយឆ្នាំ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកទទួលបានអត្ថប្រយោជន៍ពីប្រទេសកម្ពុជាចាប់តាំងពីប្រាក់ដុល្លារ ត្រូវបានប្រើប្រាស់ដោយប្រជាជនកម្ពុជា។
- ដុល្លារូបនីយកម្មបានធ្វើឱ្យធនាគារកណ្តាលបាត់ ឬដើរតួនាទីបានតិចតួចជាអ្នកឱ្យខ្ចីចុងក្រោយហើយប្រឈម និងហានិភ័យសន្ទនីយភាព។
- ដុល្លារូបនីយកម្មបានធ្វើឱ្យប្រព័ន្ធធនាគារកម្ពុជាប្រឈម និងហានិភ័យតារាងតុល្យការដោយសារតែដុល្លារូបនីយកម្មមានលក្ខណៈមិនទាំងស្រុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជានិងមានភាពងាយរងគ្រោះដែលបណ្តាលមកពីការកាន់នូវទ្រព្យសកម្ម និងអសកម្មរូបិយវត្ថុខុសគ្នា។ ការប្រើប្រាស់រូបិយ

វត្ថុតែមួយក្នុងប្រព័ន្ធហិរញ្ញវត្ថុ កាត់បន្ថយនូវហានិភ័យ ហើយនិងពង្រឹងភាពធន់និងវិបត្តិរបស់ប្រព័ន្ធហិរញ្ញវត្ថុ។

- ដុល្លារូបនីយកម្មបានដាក់កំហិតដល់ជម្រើសឧបករណ៍ និងប្រសិទ្ធភាពនៃគោលនយោបាយសេដ្ឋកិច្ច។ ការប្រើប្រាស់រូបិយវត្ថុកាន់តែទូលំទូលាយនូវគ្រប់វិស័យទាំងអស់ និងផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលពង្រឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដើម្បីជំរុញ និងរក្សានិន្តរភាពកំណើនដោយសារបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានឥទ្ធិពលដោយផ្ទាល់ទៅលើសេដ្ឋកិច្ច( ផលិតកម្មនិង ការងារ ) ។
- ដុល្លារូបនីយកម្មវាបានធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ធនាគារជាតិនៃកម្ពុជាមិនអាចបង្កើតឧបករណ៍នៃគោលនយោបាយរូបិយវត្ថុបានទេ ហើយតួនាទីរបស់ខ្លួនជាអ្នកផ្តល់ប្រាក់កម្ចីចុងក្រោយសម្រាប់ធនាគារដែលកំពុងប្រឈម និងបញ្ហាសាច់ប្រាក់មានកម្រិតយ៉ាងខ្លាំង។
- រូបិយបណ្ណជាតិអាចលេចឡើងជានិមិត្តសញ្ញានៃអធិបតេយ្យភាព និងជាតិ។
- ប្រាក់ចំណូលពី seignorage3 ត្រូវបានបង្រួមអប្បបរមា។ រដ្ឋាភិបាលសហរដ្ឋអាមេរិកទទួលបានអត្ថប្រយោជន៍ជាឯកតោភាគីពីប្រទេសកម្ពុជា ដោយសារប្រាក់ដុល្លារជាប្រាក់ដែលប្រជាជនកម្ពុជាកាន់កាប់មិនបានការប្រាក់ ប្រាក់ចំណូលប្រចាំឆ្នាំសុទ្ធដែលពីមុនត្រូវបានវាយតម្លៃក្នុងចន្លោះពី 20 ទៅ 90 លានដុល្លារក្នុងមួយឆ្នាំ។

បើទោះបីជាដុល្លារូបនីយកម្មកំពុងទទួលបានការពេញនិយមក្នុងទីផ្សារនៃប្រទេសកម្ពុជាយ៉ាងណាក៏ដោយធនាគារជាតិនៃកម្ពុជាក៏បានអំពាវនាវជំរុញ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ក្រុមហ៊ុន ស្ថាប័នជាតិនិង ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការលើកស្ទួយនិងប្រើប្រាស់រូបិយវត្ថុជាតិផងដែរ ខណៈពេលដែលការប្រើប្រាស់ប្រាក់រៀលនៅលើទីផ្សារកម្ពុជាមានប្រមាណតែ២០ភាគរយប៉ុណ្ណោះ។ បើយោងតាមអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជាលើកឡើងថា ការប្រើប្រាស់រូបិយបណ្ណដុល្លារនៅក្នុងទីផ្សារប្រទេសកម្ពុជាមានប្រមាណជា៨៣ភាគរយដោយឡែកការប្រើប្រាស់រូបិយវត្ថុប្រាក់រៀលមានមិនដល់២០ភាគរយនោះទេ។ ការប្រើប្រាស់ប្រាក់រៀល គឺសម្រាប់តែការទូទាត់តម្លៃទំនិញតូចៗហើយភាគច្រើនគេឃើញមានការប្រើប្រាស់ប្រាក់រៀលនៅតាមជនបទដោយឡែកនៅតាមទីក្រុង និងទីប្រជុំជនធំៗគេប្រើប្រាស់ដុល្លារច្រើន ។

## ៣.៣ គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ ដើម្បីគ្រប់គ្រងដុល្លារូបនីយកម្ម

គោលនយោបាយចម្បងរបស់ប្រាក់ដុល្លារ គឺកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុសំដៅទៅលើការរក្សាស្ថេរភាពថ្លៃដើម្បីរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន។ ម្យ៉ាងទៀតប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុ និងត្រូវកាត់បន្ថយដោយសារតែអជ្ញាធររូបិយវត្ថុមិនមានឥទ្ធិពលគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបរិមាណរូបិយបណ្ណបរទេស។ អាស្រ័យហេតុនេះហើយគោលនយោបាយអត្រាប្តូរប្រាក់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅសេដ្ឋកិច្ចតាមរយៈគោលនយោបាយ។ អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង៥% ដែលសមស្របសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។

សម្រាប់ប្រទេសកម្ពុជាការប្រើប្រាស់គោលនយោបាយរូបិយវត្ថុ និងឧបករណ៍គោលនយោបាយត្រូវធ្វើឡើងដោយមានការប្រុងប្រយ័ត្នខ្ពស់ និងទន់ភ្លន់ជាទីបំផុត។ នេះក៏ដោយសារតែប្រទេសកម្ពុជាជាប្រទេស

ដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ពេល គឺការចរាចរណ៍នៃរូបិយបណ្ណដោយសេរីដែលធ្វើឱ្យប្រសិទ្ធិភាពនៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា បាត់បង់ប្រសិទ្ធិភាពទៅលើឧបករណ៍គោលនយោបាយមួយចំនួនដូចជាការត្រួតត្រាអត្រាការប្រាក់ជាដើម។

**៣.៣.១ ប្រភេទនៃគោលនយោបាយរូបិយវត្ថុ**

គោលនយោបាយរូបិយវត្ថុត្រូវបានគេបែងចែកជាពីរធំៗគឺៈ

- **គោលនយោបាយរីក្លារកម្ម ឬគោលនយោបាយពង្រីក( Expansionary Policy)**ៈ គឺគោលនយោបាយដែល ត្រូវបានប្រើនៅពេលដែលអាជ្ញាធររូបិយវត្ថុប្រើឧបករណ៍នយោបាយរូបិយវត្ថុរបស់ខ្លួនដើម្បីជំរុញល្បឿនសេដ្ឋកិច្ចរបស់ខ្លួន។ គោលនយោបាយនេះធ្វើឱ្យមានការកើនឡើងការផ្គត់ផ្គង់រូបិយវត្ថុសរុបនៅក្នុងសេដ្ឋកិច្ចច្រើនជាងពេលធម្មតា ហើយវាតែងតែត្រូវបានប្រើជាប្រចាំដើម្បីប្រយុទ្ធប្រឆាំងនិងភាពអត់ការងារ (និកម្មភាព) នៅពេលដែលសេដ្ឋកិច្ចធ្លាក់ចុះដោយចាប់ផ្តើមស្តារឡើងវិញតាមរយៈការបន្ថយអត្រាការប្រាក់ក្នុងការរំពឹងថា ធ្វើឱ្យការផ្តល់ឥណទានមានការកើនឡើងជាងមុនដែលអាចបង្កភាពងាយស្រួលនៅក្នុងការពង្រីកអាជីវកម្មផងដែរ។ ចុងក្រោយវាបង្កើនតម្រូវការសរុប (តម្រូវការសរុបសម្រាប់ទំនិញ និងសេវា) នៅក្នុងសេដ្ឋកិច្ចដែលនិងជួយបង្កើនកំណើនសេដ្ឋកិច្ចដែលបានវាស់វែងដោយផលិតផលក្នុងស្រុកសរុប។ គោលនយោបាយនេះជាធម្មតានិងធ្វើឱ្យតម្លៃនៃរូបិយវត្ថុធ្លាក់ចុះ ឬថ្លៃទំនិញកើនឡើង(មានអតិផរណា) ដែលតម្រូវឱ្យមានការប្រើប្រាស់ដោយផ្ទត់ផ្ទង់។
- **គោលនយោបាយរឹតបន្តឹង ឬគោលនយោបាយពង្រួម(Contractionary Policy)**ៈ គឺគោលនយោបាយរឹតបន្តឹងដែល និងធ្វើឱ្យមានការថយចុះនៃអត្រាកំណើនសេដ្ឋកិច្ចតាមរយៈការកាត់បន្ថយបរិមាណរូបិយវត្ថុនៅក្នុងសេដ្ឋកិច្ច។ ការបន្ថយកំណើនសេដ្ឋកិច្ចនេះដើម្បីទប់ស្កាត់ការហក់ឡើងខ្ពស់នៃអត្រាអតិផរណាពេល គឺនៅពេលដែលកំណើនសេដ្ឋកិច្ចកើតឡើងដោយហេតុផលមិនសមស្របនោះវានិងជះឥទ្ធិពលយ៉ាងធំធេងទៅលើកម្រិតថ្លៃអ្នកប្រើប្រាស់ចុងក្រោយ និងប៉ះពាល់ដល់កម្រិតជីវភាពរបស់ប្រជាជនដោយជៀសមិនរួច។ គោលនយោបាយរឹតបន្តឹងអាចនាំឱ្យមានការកើនឡើងនូវភាពអត់ការងារធ្វើដោយសារតែថ្លៃដើមផលិតមានការកើនឡើងតាមរយៈ ការតំឡើងអត្រាការប្រាក់ ការកាត់បន្ថយកម្ចី និងការចំណាយរបស់អ្នកប្រើប្រាស់មានការធ្លាក់ចុះហើយអាជីវកម្មក៏និងថយល្បឿននៃការផលិតដែលជាលទ្ធផល និងធ្វើឱ្យសេដ្ឋកិច្ចមានការថមថយល្បឿនមកត្រឹមគោលដៅដែលចង់បាន។

ជារួមមកដើម្បីអនុវត្តគោលនយោបាយទាំងពីនេះបាន គេត្រូវបើឧបករណ៍គោលនយោបាយមួយចំនួនដូចជាទុនបម្រុងកាតព្វកិច្ច កម្ចីអប្បហារ និងប្រតិបត្តិការបើកចំហរជាដើម្បីជាដែលឧបករណ៍និយមប្រើជាងគេ។ និយាយដោយឡែកគោលដៅនៃគោលនយោបាយទាំងពីរខាងលើ គឺមានគោលដៅសម្រេចបាននូវគោលដៅអតិផរណាតាមរយៈការប្រែប្រួលនៃបរិមាណរូបិយវត្ថុ(បង្កើន ឬបន្ថយ)នៅក្នុងទីផ្សារ។

**៣.៣.២ គោលដៅនៃគោលនយោបាយរូបិយវត្ថុ**

គោលដៅចម្បងបំផុតនៃការអនុវត្តគោលនយោបាយរូបិយវត្ថុគឺរក្សាស្ថិរភាពថ្លៃ។ ស្ថិរភាពថ្លៃដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបស្ថិរភាពនៃអតិផរណា ត្រូវបានបណ្តាលធនាគារកណ្តាលនៅលើពិភពលោកចាត់ទុកថាជាគោលដៅដ៏សំខាន់បំផុត ពីព្រោះការកើនឡើងនៃកម្រិតថ្លៃទំនិញ និងសេវាអាចបង្កើតឱ្យមានភាពមិនប្រាកដប្រជានៅក្នុងសេដ្ឋកិច្ចដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តរបស់អ្នកប្រើប្រាស់ អ្នកវិនិយោគ និង

រដ្ឋាភិបាលហើយជាលទ្ធផលបង្កើតឱ្យមានប្រព័ន្ធហិរញ្ញវត្ថុដែលមិនមានប្រសិទ្ធភាពនិងប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។ លើសពីនេះអតិផរណាខ្ពស់ហួសហេតុអាចធ្វើឱ្យសាធារណជនបាត់ជំនឿទុកចិត្តទៅលើរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូលដែលអាចបង្កឱ្យមានភាពវឹកវរនៅក្នុងសង្គមដោយប្រាក់ចំណូលរបស់ប្រជាពលរដ្ឋមិនអាចទប់ទល់ និងការបន្តឡើងថ្លៃនៃទំនិញ និងសេវាបាន។

ក្រៅពីគោលដៅរក្សាស្ថិរភាពថ្លៃដ៏ចម្បងនេះធនាគារកណ្តាលក៏មានគោលដៅផ្សេងៗចំនួន ៥ ទៀតផងដែរសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុដែលរួមមាន កម្រិតខ្ពស់នៃភាពមានការងារធ្វើ កំណើនសេដ្ឋកិច្ច ស្ថិរភាពទីផ្សារហិរញ្ញវត្ថុ ស្ថិរភាពអត្រាការប្រាក់ និងស្ថិរភាពអត្រាប្តូរប្រាក់។

### ៣.៣.៣ គោលនយោបាយរូបិយវត្ថុនៃធនាគារជាតិដើម្បីគ្រប់គ្រងដុល្លារូបនីយកម្ម

### ក.ការគ្រប់គ្រងដុល្លារូបនីយកម្ម

ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក ដែលកំពុងប្រើប្រាស់ប្រាក់ដុល្លារយ៉ាងច្រើនលើសលប់នៅលើទីផ្សាររបស់ខ្លួន។ នៅក្នុងនោះដែរមានការចាយវាយ ឬការប្រើប្រាស់ប្រាក់ដុល្លារមានកម្រិតខ្ពស់ជាងប្រាក់រៀល ដូច្នេះប្រទេសកម្ពុជាយើងកំពុងក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតដុល្លារូបនីយកម្មខ្ពស់បានធ្វើឱ្យប្រទេសកម្ពុជារងនូវឥទ្ធិពលពីខាងក្រៅ ហើយអាចនិងប្រឈមនិងហានិភ័យជាចម្បងដែលអាចឱ្យប៉ះពាល់ទៅដល់សេដ្ឋកិច្ចកម្ពុជាផងដែរ។

ទើបប្រទេសកម្ពុជាត្រូវលើកស្ទួយកម្ពស់ប្រាក់រៀលបន្ថែម ព្រមទាំងធ្វើឱ្យអ្នកវិនិយោគិនក្នុងស្រុកចាប់ផ្តើមឱ្យតម្លៃដល់ការចរាចរណ៍សាច់ប្រាក់នេះពួកគេនិយាយថាការប្រើប្រាស់ជំនួសឱ្យប្រាក់ដុល្លាររបស់អាមេរិកផងដែរប្រាក់រៀលច្រើនបានធ្វើឱ្យប្រាក់រៀលមានលំនឹង និងជួយដល់ប្រជាកសិករមិនឱ្យមានបញ្ហាប្រឈមក្នុងការប្តូរប្រាក់រៀលទៅជាប្រាក់ដុល្លារអាមេរិក។ ហេតុនេះទើបប្រទេសកម្ពុជាចាំបាច់ត្រូវបង្កើតភាពឯករាជ្យពីការប្រើប្រាស់រូបិយបណ្ណដើម្បីមើលលទ្ធភាពនៃការគ្រប់គ្រងដុល្លារូបនីយកម្មកាន់តែមានប្រសិទ្ធភាពខ្ពស់។ គោលបំណងក្នុងការគ្រប់គ្រងដុល្លារូបនីយកម្មមានដូចខាងក្រោម ៖

-ដើម្បីលើកស្ទួយទៅលើការប្រើប្រាស់រូបិយវត្ថុជាតិ

-ធ្វើឱ្យមានស្ថេរភាពអត្រាប្តូរប្រាក់

-ផ្តល់តម្លៃទៅលើប្រាក់រៀលដែលជារូបយវត្ថុជាតិ

-អាចបង្កើតចំណូលចូលប្រទេសជាតិ

-ធ្វើឱ្យមានស្ថេរភាពអត្រាប្តូរប្រាក់រៀល។ល។

ជារួមប្រសិនបើយើងចង់គ្រប់គ្រងឱ្យមានភាពរឹងមាំចំពោះដុល្លារូបនីយកម្ម យើងគួរមានការប្រើប្រាស់នៅរូបិយវត្ថុជាតិឱ្យបានច្រើនទើបរាជរដ្ឋាភិបាលធ្វើការគ្រប់គ្រងបានប្រសើរ។ ដូចជាបច្ចុប្បន្ននេះដែររាជរដ្ឋាភិបាលបានកំពុងធ្វើការប្រមូលចំណូលជាប្រាក់រៀលដើម្បីបង្កើនការគ្រប់គ្រងឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយក៏ជាការអនុវត្តគោលនយោបាយសារពើពន្ធត្រូវបានកំណត់ដោយបរិមាណដុល្លារអាមេរិកដ៏ច្រើននៅក្នុងសេដ្ឋកិច្ច។ ប្រសិនបើរដ្ឋាភិបាលមានបំណងចង់បង្កើតចំណាយសាធារណៈរាជរដ្ឋាភិបាលមិនអាចខ្ចីប្រាក់ជារូបិយបណ្ណពីទីផ្សារក្នុងស្រុកបានទេដោយសារតម្រូវការប្រាក់ដុល្លារកើនឡើងខ្លាំងដែរ និងធ្វើឱ្យដុល្លារូបនីយកម្មនៅកម្ពុជាកាន់តែកាន់ឡើង។ រីឯប្រទេសមួយចំនួនប្រើប្រាស់ប្រាក់ដុល្លារសម្រាប់ទិញទំនិញយកមកលក់ក្នុងស្រុកដែលធ្វើឱ្យទំនិញក្នុងប្រទេសនោះដាក់តម្លៃជាដុល្លារជាហេតុធ្វើឱ្យប្រជាពលរដ្ឋតាមបណ្តាប្រទេសនោះ

ប្រើប្រាស់ដុល្លារច្រើនជាងរូបិយបណ្ណជាតិខ្លួនទៅទៀត។ ឧទាហរណ៍ប្រទេសកម្ពុជាដែលយើងមើលឃើញស្រាប់ហើយថាស្ទើរតែគ្រប់មុខទំនិញ និងថ្លៃសេវាកម្មផ្សេងៗគិតជាប្រាក់ដុល្លារដូច្នេះប្រជាពលរដ្ឋខ្មែរចូលចិត្តប្រើប្រាស់ប្រាក់ដុល្លារជាងប្រាក់រៀលដោយមិនចាំបាច់គិតពីអត្រាប្តូរប្រាក់ឡើងចុះរាល់ពេលទិញទំនិញ ឬសេវាកម្មដូចប្រាក់រៀលនោះទេ។ ហើយការចរាចរណ៍រូបិយបណ្ណបរទេស ឬដុល្លារច្រើនពេកអាចធ្វើឱ្យបាត់បង់តម្លៃនៃប្រាក់រៀលដែលជារូបិយវត្ថុតំណាងជាតិខ្មែរយើងនេះ។ ដោយហេតុនេះហើយបានជាប្រទេសកម្ពុជាបានលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យមានស្ថេរភាពក្នុងការគ្រប់គ្រងដុល្លារូបនីយកម្មផងដែរ។ ប្រសិនបើទីផ្សារមានការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនប្រសទេសកម្ពុជា និងអាចកាត់បន្ថយនូវការប្រើប្រាស់រូបិយបណ្ណបរទេសទើបមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងដុល្លារូបនីយកម្មនៅកម្ពុជា។

**ខ. គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ**

ធនាគារជាតិនៃកម្ពុជា បានចេញសេចក្តីជូនដំណឹងស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៤៨ ក្រោមការចូលរួមពីលោក **ជា ចាន់តូ** អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានគណៈកម្មាធិការគោនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាលើបច្ចុប្បន្នភាពនៃស្ថានភាពសេដ្ឋកិច្ចពិភពលោកវឌ្ឍនភាព និងបញ្ហាប្រឈមនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាព្រមទាំងគោលនយោបាយរូបិយវត្ថុសម្រាប់អនុវត្តនាគ្រាខាងមុខ។

ក្នុងនោះគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុបានសម្រេចបន្តអនុវត្តគោលនយោបាយរូបិយវត្ថុចំនួន៥ រួមមាន៖

១.បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ដោយប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានស្ថិរភាពតាមរយៈការធ្វើអន្តរាគមន៍ផ្អែកលើការប្រែប្រួលនៃទីផ្សារ។

២.បន្តរក្សាការផ្គត់ផ្គង់សន្ទនីយភាព ជាប្រាក់រៀលសម្រាប់បំពេញតម្រូវការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

៣.ដាក់ឱ្យអនុវត្តឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (MLF) នៅត្រីមាសទី។

៤.បន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ឱ្យកាន់តែទូលំទូលាយតាមរយៈការបង្កើនការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់និងតួនាទីនៃប្រាក់រៀលនៅក្នុងសេដ្ឋកិច្ច និងសង្គម។

៥.ពង្រឹងការអនុវត្តប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការតម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានប្រាក់កម្ចីយ៉ាងហោច ១០% ជាប្រាក់រៀល។

**លោកស្រី ជា សិរី ទេសាភិបាលរងនៃ NBCលោកស្រីនិយាយថា៖** ការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើន និងផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តនយោបាយរូបិយវត្ថុ និងអត្រាប្តូរប្រាក់កាន់តែមានប្រសិទ្ធភាពពិសេសការកំណត់អត្រាការប្រាក់គោល និងការផ្តល់សាច់ប្រាក់បន្ថែមដល់សេដ្ឋកិច្ចដែលអាចមានឥទ្ធិពលទៅលើអត្រាការប្រាក់ទីផ្សារ ការវិនិយោគ និងផលិតកម្មឈានទៅជំរុញឱ្យមានការបង្កើតការងារ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន។ ប្រាក់រៀល គឺជារូបិយវត្ថុជាតិរបស់យើងទាំងអស់គ្នាដូច្នេះការចូលរួមប្រើប្រាស់ប្រាក់រៀលពិតជាបានរួមចំណែកដោយផ្ទាល់ឬប្រយោលដល់កិច្ចការពារ និងពង្រឹងអធិបតេយ្យសេដ្ឋកិច្ច អត្តសញ្ញាណជាតិ សាមគ្គីភាព ការរីកចម្រើនសេដ្ឋកិច្ច និងសង្គម។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានធ្វើការសិក្សាអស់មួយរយៈកន្លងមក ក្រុមរបស់យើងខ្ញុំបានផ្តុំនូវព័ត៌មានសំខាន់ៗ ជាច្រើនទុកជាទុនដើម្បីវិភាគ ស្ទាបស្ទង់ វាស់វែង និងវាយតម្លៃពីផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា។ ក្នុងនោះដែរ ក្រុមយើងខ្ញុំក៏បានសង្កេតឃើញពីចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួន ដែលកើតមានឡើងដូចខាងក្រោម ៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ការប្រើប្រាស់ប្រាក់ដុល្លារអាចជំរុញឱ្យប្រទេសកម្ពុជាមានសក្តានុពលទៅលើវិស័យហិរញ្ញវត្ថុ ដូចជា សេវាកម្មធនាគារ និងមីក្រូហិរញ្ញវត្ថុដោយជាការសំខាន់ នោះការផ្តល់ប្រាក់កម្ចីពីធនាគារសម្រាប់ការធ្វើពាណិជ្ជកម្មផ្សេងៗស្ទើរតែមួយរយភាគរយត្រូវបានផ្តល់ឱ្យជាលុយដុល្លារ។
- ប្រាក់ដុល្លារបានជួយសម្រួលដល់ការទូទាត់ ចំពោះការទិញទំនិញនិងថ្លៃសេវាកម្មផ្សេងៗទៀត ជាពិសេសសម្រាប់អ្នកនាំចេញទំនិញទៅក្រៅប្រទេសការប្រើប្រាស់លុយដុល្លារបានផ្តល់ផលចំណេញជាច្រើននៅពេលដែលមានអត្រាប្តូរខ្ពស់។
- ប្រាក់ដុល្លារបានធ្វើឱ្យមានកំណើននៃការវិនិយោគមកពីបណ្តាប្រទេសផ្សេងៗទាំងទ្វីបអាស៊ី និងទ្វីបអឺរ៉ុប។
- ការប្រើប្រាស់លុយដុល្លារអាចជួយទប់ស្កាត់នូវលំហូរចេញនៃដើមទុន និងជំរុញការលើកទឹកចិត្តដល់សាធារណៈជននៅក្នុងការសន្សំប្រាក់ជាមួយ និងធនាគារក្នុងប្រទេសដោយសារតែគ្មានការប្រឈមនិងហានិភ័យនូវអត្រាប្តូរប្រាក់។
- អាចសម្រួលដល់សមាហរណកម្មពាណិជ្ជកម្ពុជាទៅក្នុងសេដ្ឋកិច្ចពិភពលោកដោយមិនបានធ្វើឱ្យវិនិយោគិនបរទេសព្រួយបារម្ភហានិភ័យអត្រាប្តូរប្រាក់ និងជួយកាត់បន្ថយចំណាយពីការប្តូររូបិយបណ្ណ។
- ដុល្លារអាមេរិកដែលជារូបិយបណ្ណដ៏មានស្ថិរភាពបានជួយកម្ពុជាឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើតបរិយាកាសដែលមានអំណោយផលសម្រាប់ការធ្វើជំនួញ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- ការអនុវត្តនគោលនយោបាយរូបិយវត្ថុអាច និងបាត់បង់។
- ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកយ៉ាងទូលំទូលាយដូចជាពេលបច្ចុប្បន្ននេះមានន័យថា ទោះបីជាចង់មិនចង់ មួយផ្នែកធំនៃគោលនយោបាយរូបិយវត្ថុរបស់កម្ពុជា ត្រូវបានផ្ទេរទៅឱ្យធនាគារកណ្តាលអាមេរិកជាអ្នកចាត់ចែងជំនួសធនាគារជាតិកម្ពុជាវិញ។
- ការប្រើប្រាស់ប្រាក់ដុល្លារបានរារាំងចំពោះការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ ព្រោះធនាគារជាតិមិនមានឧបករណ៍ហិរញ្ញវត្ថុគ្រប់គ្រាន់ឡើយ។
- ការប្រើប្រាស់រូបិយបណ្ណអាមេរិកច្រើនធ្វើឱ្យរាជរដ្ឋាភិបាលបាត់បង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រៀល។
- ការប្រើប្រាស់ប្រាក់ដុល្លារច្រើនធ្វើឱ្យការប្រើប្រាស់រូបិយវត្ថុជាតិមានការធ្លាក់ចុះ

- ប្រឈមនឹងហានិភ័យនៃអត្រាប្តូរប្រាក់

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

## ៥.១ សេចក្ដីសន្និដ្ឋាន

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវ និងវិភាគទៅលើប្រធានបទ "**ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**" រួចមកក្រុមរបស់យើងខ្ញុំអាចយល់ថាការប្រើប្រាស់ដុល្លាររូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជាមានការហូរចូលយ៉ាងច្រើនជាបន្តបន្ទាប់ដោយសារការបើកចំហសេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យមានលំហូរវិនិយោគដើមទុនជាប្រាក់ដុល្លារអាមេរិកចូលមកកម្ពុជា។ ភាពទន់ខ្សោយនៃគោលនយោបាយរាជរដ្ឋាភិបាលនិងធនាគារកណ្ដាលបានធ្វើឱ្យប្រជាពលរដ្ឋបាត់បង់ជំនឿទុកចិត្តលើប្រាក់រៀល ហើយតម្រូវការប្រាក់រៀលនៅលើទីផ្សារក៏បានធ្លាក់ចុះជាលំដាប់ដែលនាំឱ្យពួកគេងាកមករកប្រាក់ដុល្លារអាមេរិកដើម្បីបំពេញនូវតម្រូវការរបស់ពួកគេ។

ដុល្លាររូបនីយកម្មបាននាំមកនូវទាំងផលប្រយោជន៍និងហានិភ័យចំពោះកម្ពុជា។ ចំពោះអត្ថប្រយោជន៍ដុល្លាររូបនីយកម្មបានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុកម្ពុជាហើយបានបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់ និងអន្តរជាតិក្នុងពេលដែលកម្រិតសមាហរណកម្មកម្ពុជានៅមានកម្រិតដ៏ទាបនៅឡើយនាអំឡុងពេលដែលសេដ្ឋកិច្ចកំពុងចាប់ផ្ដើមលូតលាស់។ ផលប្រយោជន៍ទាំងនោះត្រូវបានឆ្លុះបញ្ចាំងក្នុងរូបភាព៖ ការកាត់បន្ថយថ្លៃដើមនៃដើមទុនសម្រាប់ការវិនិយោគ ការជួយអភិវឌ្ឍវិស័យហិរញ្ញវត្ថុក្នុងពេលដែលប្រជាជនកម្ពុជាបានបាត់បង់ជំនឿទុកចិត្តមកលើប្រព័ន្ធហិរញ្ញវត្ថុ និងការបង្កើនវិន័យវិស័យសារពើពន្ធ ការសម្រួលការទូទាត់ពាណិជ្ជកម្មអន្តរជាតិ ការទាក់ទាញការវិនិយោគពីបរទេសកម្រិតទាបនៃអតិផរណា ស្ថិរភាពអត្រាប្ដូរប្រាក់ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចហើយដុល្លាររូបនីយកម្មបានជួយស្ដារស្ថានភាពម៉ាក្រូសេដ្ឋកិច្ចឱ្យប្រសើរឡើងវិញ។ នៅពេលដែលសេដ្ឋកិច្ចប្រទេសកម្ពុជាកាន់តែមានការរីកចម្រើន និងប្រទាក់ក្រឡាដុល្លាររូបនីយកម្មមិនត្រឹមតែធ្វើឱ្យកម្ពុជាខាតបង់ចំណូលពីការបោះពុម្ពក្រដាសប្រាក់រៀលប៉ុណ្ណោះទេថែមទាំងអាចបង្កជាហានិភ័យ និងមានគុណវិបត្តិកាន់តែច្រើនចំពោះសេដ្ឋកិច្ចកម្ពុជា ជាពិសេសធ្វើឱ្យមានភាពផុយស្រួយទៅនឹងការប៉ះទង្គិចទាំងដោយកត្តាក្នុងស្រុក និងខាងក្រៅ។ ម្យ៉ាងទៀតដុល្លាររូបនីយកម្មបានក្លាយជាឧបសគ្គមួយក្នុងការជំរុញសមាហរណកម្មក្នុងតំបន់ផងដែរនៅក្នុងក្របខ័ណ្ឌសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលប្រទេសនីមួយៗខិតខំប្រើប្រាស់រូបិយវត្ថុផ្ទាល់ខ្លួនក្នុងប្រតិបត្តិការសេដ្ឋកិច្ចតំបន់ដោយកាត់បន្ថយការពឹងផ្អែកលើប្រាក់ដុល្លារអាមេរិក។ លើសពីនេះការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបានបង្កជាការលំបាកខ្លាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដោយវាបានកាត់បន្ថយប្រសិទ្ធភាពគោលនយោបាយ និងរារាំងដល់ការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុដូចជាអត្រាការប្រាក់ជាដើម។ ជាងនេះទៅទៀតដោយរូបិយវត្ថុជាតិតំណាងឱ្យអត្តសញ្ញាណ វប្បធម៌ សាសនា និងប្រវត្តិសាស្ត្ររបស់ជាតិយើងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក និងការមិនចូលរួមប្រើប្រាស់រូបិយវត្ថុរបស់ជាតិយើង គឺមានន័យថាមិនបានចូលរួមលើកស្ទួយដល់អត្តសញ្ញាណជាតិរបស់យើង។

សរុបមកយោងតាមការសិក្សាស្រាវជ្រាវ និងពិភាក្សាគ្នាយ៉ាងសកម្មនៃសារណារបស់ក្រុមយើងខ្ញុំទៅលើប្រធានបទ "**ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា**" រួចមកក្រុមរបស់យើងខ្ញុំអាចសន្និដ្ឋានបានថាដុល្លាររូបនីយកម្មបានផ្ដល់នូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជានៅក្នុងដំណាក់កាលដែលកម្ពុជាកំពុងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងរយៈពេលវែង នៅពេលដែលសេដ្ឋកិច្ចកម្ពុជាចាប់ផ្ដើមមានការរីកចម្រើនជឿនលឿន

និងមានទំហំកាន់តែធំដុល្លារូបនីយកម្ម និងរារាំងដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុដើម្បីការពារប្រព័ន្ធហិរញ្ញវត្ថុសេដ្ឋកិច្ចពីវិបត្តិហានិភ័យ និងបញ្ហាប្រឈមដែលបណ្តាលមកពីកត្តាខាងក្នុង និងខាងក្រៅ។ ដូចនេះដើម្បីបន្តជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពប្រុងប្រយ័ត្ននិងហានិភ័យទាប ព្រមទាំងដើម្បីលើកស្ទួយដល់អត្តសញ្ញាណជាតិ យើងប្រជាពលរដ្ឋខ្មែរទាំងអស់គួរចាប់ផ្តើមងាកមកប្រើប្រាស់រូបិយវត្ថុជាតិ "ប្រាក់រៀល" និងកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកបន្តិចម្តងៗ។

## ៥.២ ការផ្តល់អនុសាសន៍

ក្រោយពីបានឆ្លងកាត់នូវការធ្វើការសេចក្តីសន្និដ្ឋានទៅលើប្រធានបទ **ផលប៉ះពាល់ដុល្លាររូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា** រួចមកក្រុមយើងខ្ញុំយល់ថា ដើម្បីប្រើប្រាស់ប្រាក់ដុល្លារដែលជារូបិយបណ្ណបរទេសប្រកបដោយភាពប្រុងប្រយ័ត្ន និងហានិភ័យទាប ធនាគារជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគួរចេញនូវគោលនយោបាយហិរញ្ញវត្ថុ និងវិធានការគាំទ្រការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលគួរត្រូវបានដាក់ចេញដោយស្របតាមគោលការណ៍យន្តការទីផ្សាររួមមាន៖

- ពង្រឹងនូវគោលយោបាយរូបិយវត្ថុដើម្បីធ្វើការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ រក្សាអត្រាអតិផរណា ឬអត្រាការប្រាក់ក្នុងទិសដៅរក្សាស្ថិរភាពថ្លៃ បង្កើតការងារ និងជំរុញកំណើនសេដ្ឋកិច្ច។
- ធនាគារជាតិត្រូវមានវិធានការទប់ស្កាត់នូវការប្រើប្រាស់ប្រាក់ដុល្លារនៅក្នុងប្រទេសកម្ពុជា ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជំនឿទុកចិត្តមកលើប្រាក់រៀលហើយងាយស្រួលក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យកាន់ប្រសើរឡើង និងជួយលើកស្ទួយប្រាក់រៀលផងដែរ។
- ការប្រើប្រាស់ប្រាក់រៀលកាន់តែច្រើនជួយកាត់បន្ថយប្រាក់ដុល្លារនៅក្នុងស្រុក និងជួយបន្ថែមនូវកំណើននៃការបោះពុម្ពប្រាក់រៀលរបស់រាជរដ្ឋាភិបាលថែមទៀតផង។
- ធនាគារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវតែជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាសាធារណជននានាប្រើប្រាស់ប្រាក់រៀលដូចជាការតម្លើងសន្សឹមៗនៃនូវអត្រាប្រាក់បម្រុងកាតព្វកិច្ចលើប្រាក់បញ្ញើ និងកម្ចីជាប្រាក់ដុល្លារអាមេរិក ការកាត់បន្ថយជាបណ្តើរៗទៅលើអត្រាការប្រាក់ឥណទានជាប្រាក់រៀល និងការយកកម្រៃសេវាផ្សេងៗជាប្រាក់រៀលទាបជាងរូបិយប័ណ្ណ។
- ចូលរួមផ្សព្វផ្សាយអប់រំជាសាធារណៈឱ្យយល់ដឹងពីរប្រើប្រាស់រូបិយវត្ថុជាតិ និងចូលរួមលើកស្ទួយកំណើនសេដ្ឋកិច្ច និងប្រទេសជាតិទាំងមូលទៅដល់សាធារណៈជនកូនចៅជំនាន់ក្រោយឱ្យយល់ដឹងកាន់តែច្បាស់។
- គួរតែប្រើប្រាស់ប្រាក់រៀលឱ្យបានច្រើនដើម្បីជៀសវាងនូវហានិភ័យនៃអត្រាប្តូរប្រាក់។

# ឯកសារយោង

# ឯកសារយោង


- *សារណាប្រឡងជំនាន់ទី១៨ ការជួញដូរម្ហូបត្រនៅកម្ពុជា ទំព័រទី៧*
- *សៀវភៅ រូបិយវត្ថុ និងធនាគារ ភាគ១ ទំព័រទី៣៦-៣៧*
- *សារណាប្រឡងជំនាន់ទី១៧ ដំណើរការនៃការផ្ដល់ឥណទានរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទំព័រទី៥-៧*
- *សារណាប្រឡងជំនាន់១៨ ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន អេឡិច. & ម៉ិចត្រេឌីង ឯ.ក ទំព័រទី ៦-៧*
- *ស្នាដៃស្រាវជ្រាវវគ្គកាលទី៥ ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា ទំព័រ ៣៣-៣៤*
- *https://www.sangapac.com/dictionary/pha/3733*
- *https://www.kampucheathmey.com/business-economic/529638*
- *https://corporatefinanceinstitute.com/resources/economics/dollarization/*
- *https://www.thebalancemoney.com/what-is-dollarization-5214456*
- *https://economy.ams.com.kh/43671*
- *https://www.khsearch.com/qna/27047*
- *https://web.facebook.com/story.php?story_fbid=2444569705869689&id=2219692831690712&rdid=dtDa6SjoPN856B19*
- *https://km.wikipedia.org/wiki/*
- *https://www.youtube.com/watch?v=1Ju2LtPuIGA*
- *https://www.sangapac.com/dictionary/ko/915*
- *https://www.sciencedirect.com/topics/social-sciences/economic-history*
- *https://www.youtube.com/watch*
- *https://kohsantepheapdaily.com.kh/article/139767.html*
- *https://economy.ams.com.kh/finance/news/understand-the-history-of-riel-vs-dollar-in-cambodia/*
- *https://kakcent.com/dollarization-cambodia/*
- *https://cnc.com.kh/index.php/detail/news/4270*
- *https://www.nbc.gov.kh*
- *https://thmeythmey.com/*
- *https://www.nbc.gov.kh/monetary_policy/overview.php*
- *https://www.nbc.gov.kh/download_files/publication/*
- *https://www.facebook.com/CambonomicTimes/posts*

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ



កម្មវិធីប្រកួតប្រជែងស្នាដៃស្រាវជ្រាវ
វដ្តកាលទី ៥
VIA.013.244
អែម ចាន់ណាក់
ស្រាវជ្រាវ/2023
ប្រធានបទ៖
"ឥទ្ធិពលនៃដុល្លារូបនីយកម្មមកលើសេដ្ឋកិច្ចកម្ពុជា"

ក្រសួងអប់រំយុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងចំណូលរបស់ក្រុមហ៊ុន អេឡិច. & ម៉ិច ត្រេឌីង ៦.ក

ជំនាញ: គណនេយ្យ

រាជធានីភ្នំពេញ - ឆ្នាំ២០២១

PHNOM PENH - 2021

វិទ្យាស្ថាន វ៉ាន់ដាគណនេយ្យ
Vanda Institute of Accounting



# មីក្រូសេដ្ឋកិច្ចវិទ្យា
# Microeconomics

រក្សាសិទ្ធិគ្រប់យ៉ាងដោយ វិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី៣ (២០១២)
សំរាប់ប្រើប្រាស់ផ្ទៃក្នុង

បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE

ភាគ១




# រូបិយវត្ថុ និងធនាគារ
# MONEY AND BANKING

រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា

បោះពុម្ពលើកទី៥ (២០១៥)

សម្រាប់ប្រើផ្ទៃក្នុង

ក្រសួងអប់រំយុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការផ្តល់ឥណទានរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី

## ជំនាញៈ ហិរញ្ញវត្ថុ និងធនាគារ

VIA .013.156
ម៉ង់ ម៉េងលីង
Library/2020

រាជធានីភ្នំពេញ -ឆ្នាំ២០២០
PHNOM PENH, 2020